ព្រះរាជាណាចក្រកម្ពុជា

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# របាយការណ៍ប្រចាំឆ្នាំ

# ស្តីពី

# ការអនុវត្តផែនការសកម្មភាព និងថវិកា

# ឆ្នាំ២០១៥ របស់ គ.ជ.អ.ប

រៀបចំដោយលេខាធិការដ្ឋាន គ.ជ.អ.ប

ខែមករា ឆ្នាំ២០១៦

# អារម្ភកថា

ការរៀបចំ និងការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥របស់ គ.ជ.អ.ប គឺជាអន្តរកាលនៃការផ្ទេរការអនុវត្តផែនការអនុវត្តដំណាក់កាលទី១ (**ផអ៣ទី១**) ដើម្បីចាប់ផ្តើមអនុវត្តផែនការអនុវត្តដំណាក់កាលទី២(**ផអ៣ទី២**)នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ តាមបែបផែន និងយុទ្ធសាស្ត្រថ្មីៗដែលបានកំណត់។ ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥ របស់ គ.ជ.អ.ប បានកំណត់នូវចំណុចដៅជាអាទិភាពសំខាន់ៗចំនួន២០ ដែលត្រូវអនុវត្តនៅក្នុងឆ្នាំ២០១៥។ ចំណុចដៅជាអាទិភាពទាំងនេះពាក់ព័ន្ធនឹងការបន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងកិច្ចដំណើរការកំណែទម្រង់ ការលើកកម្ពស់គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ការពង្រឹងការគ្រប់គ្រងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ការបន្តជំរុញកិច្ចដំណើរការផ្ទេរមុខងារនិងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងការធ្វើវិមជ្ឈការហិរញ្ញវត្ថុ។

ជារួម ក្នុងការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥របស់ គ.ជ.អ.ប នេះ ស្ថាប័នអនុវត្តទាំងអស់ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបានចូលរួមយ៉ាងសកម្ម និងមានការទទួលខុសត្រូវខ្ពស់ក្នុងការអនុវត្តសកម្មភាពជាអាទិភាពនានាដែលបានកំណត់។ របាយការណ៍ប្រចាំឆ្នាំស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥នេះ ឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពនៃការសម្រេចបាននូវចំណុចដៅជាអាទិភាពនីមួយៗដោយធ្វើការប្រៀបធៀបជាមួយនឹងសូចនាករនៃចំណុចដៅដែលបានកំណត់ ព្រមទាំងកំណត់នូវបញ្ហាប្រឈមជាគន្លឹះនានាដែលត្រូវបន្តដោះស្រាយនៅក្នុងឆ្នាំ២០១៦។

ក្នុងនាមលេខាធិការដ្ឋាន គ.ជ.អ.ប សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប** ដែលបានដឹកនាំ និងបានផ្តល់គោលការណ៍ណែនាំតម្រង់ទិសជាគន្លឹះៗក្នុងការរៀបចំ និងការអនុវត្តកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ សូមថ្លែងអំណរគុណចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ដែលជាសមាជិក សមាជិកានៃគ.ជ.អ.ប ជាថ្នាក់ដឹកនាំ ជាមន្ត្រីនៃស្ថាប័នអនុវត្ត ជាដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធនានា ដែលបានខិតខំប្រឹងប្រែងផ្តល់កិច្ចសហការ ផ្តល់ការគាំទ្រ និងចូលរួមចំណែកយ៉ាងសកម្មក្នុងការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥ របស់ គ.ជ.អ.ប ឱ្យសម្រេចបានលទ្ធផលជាច្រើនដូចដែលបានរំពឹងទុក។

របាយការណ៍នេះត្រូវបានពិនិត្យ និងអនុម័តក្នុងកិច្ចប្រជុំលើកទី១១ របស់ គ.ជ.អ.ប នាថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦។

រាជធានីភ្នំពេញថ្ងៃទី២១ ខែមករា ឆ្នាំ ២០១៦

ប្រធានលេខាធិការដ្ឋានគ.ជ.អ.ប

សក់ សេដ្ឋា

# មាតិកា


សេចក្តីផ្តើម ........ 01

I. វឌ្ឍនភាព បញ្ហាប្រឈម ការវិភាគ និងដំណោះស្រាយនានា ........ 02

១. ការគ្រប់គ្រងកិច្ចដំណើរការកំណែទម្រង់ ........ 02

១.១. ចំណុចជាអាទិភាព ........ 02

- ការពង្រឹងប្រសិទ្ធភាពនៃការរៀបចំកិច្ចប្រជុំនានារបស់គ.ជ.អ.ប ........ 02
- ការរៀបចំនិងដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រទំនាក់ទំនង ........ 02
- ការពិនិត្យ និងកែសម្រួលនីតិវិធីនានារបស់លេខាធិការដ្ឋានគ.ជ.អ.ប ........ 03

១.២. វឌ្ឍនភាព ........ 03

១.៣. បញ្ហាប្រឈម ........ 05

១.៤. ការវិភាគ និងដំណោះស្រាយ ........ 05

២. គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ........ 06

២.១. ចំណុចដៅជាអាទិភាព ........ 06

- ការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គម ........ 06
- ការរៀបចំ និងអនុវត្តវិធានគ្រប់គ្រងផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុក ........ 06
- ការរៀបចំ និងដាក់ឱ្យអនុវត្តនូវប្រព័ន្ធអធិការកិច្ចលើការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ........ 07
- ការពង្រឹងសមត្ថភាពនៃសមាគមជាតិរដ្ឋបាលថ្នាក់ក្រោមជាតិ. ........ 07
- ការរៀបចំ និងដាក់ឱ្យអនុវត្តសៀវភៅណែនាំស្តីពីនីតិវិធីរដ្ឋបាលរាជធានីខេត្ត និងក្រុង ស្រុក ខណ្ឌ ........ 07
- ការរៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រង ........ 08

២.២. វឌ្ឍនភាព ........ 08

២.៣. បញ្ហាប្រឈម ........ 10

២.៤. ការវិភាគ និងដំណោះស្រាយ ........ 10

៣. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស ........ 11

៣.១. ចំណុចដៅជាអាទិភាព ........ 11

- លក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ........ 12
- វគ្គបណ្តុះបណ្តាលអំពីការបញ្ជ្រាបយេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រី. ........ 12
- ការរៀបចំបង្កើតមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត ........ 12

៣.២. វឌ្ឍនភាព ........ 13

២.៣. បញ្ហាប្រឈម ........ 14

២.៤. ការវិភាគ និងដំណោះស្រាយ ........ 14

៤. ការផ្ទេរមុខងារ និងធនធានក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន ........ 15

៤.១. ចំណុចដៅជាអាទិភាព ........ 15

- ការធ្វើសេចក្តីសម្រេចចិត្តអំពីការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ........ 15

- ការផ្ទេរមុខងារផ្តល់សេវាទីប្រជុំជនពីខេត្តទៅឱ្យក្រុង ស្រុក ........ 16
- ការរៀបចំលិខិតបទដ្ឋាននានាស្តីពីមុខងារជាជម្រើស និងសេវាសង្គម ........ 16

**៤.២. វឌ្ឍនភាព** ........ 16

**៤.៣. បញ្ហាប្រឈម** ........ 18

**៤.៤. ការវិភាគ និងដំណោះស្រាយ** ........ 18

**៥. វិមជ្ឈការហិរញ្ញវត្ថុ** ........ **19**

**៥.១. ចំណុចដៅជាអាទិភាព** ........ 19

- ការកែលំអប្រព័ន្ធ និងនីតិវិធីគ្រប់គ្រងមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់........ 20
- ការកៀរគរធនធានពីដៃគូអភិវឌ្ឍន៍ដើម្បីគាំទ្រមូលនិធិក្រុងស្រុកផ្នែកអភិវឌ្ឍន៍ ........ 20
- យន្តការផ្តល់ហិរញ្ញប្បទានមានឡាប់ល័ក្ខខ័ណ្ឌ........ 20
- ការបង្កើតលេខាធិការដ្ឋានទទួលបន្ទុកយន្តការមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ. ........ 21
- សេចក្តីណែនាំបច្ចេកទេសស្តីពីការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ........ 21

**៥.២. វឌ្ឍនភាព** ........ 21

**៥.៣. បញ្ហាប្រឈម** ........ 23

**៥.៤. ការវិភាគ និងដំណោះស្រាយ** ........ 24

II. **ស្ថានភាពហិរញ្ញវត្ថុ** ........ 25

III. **ទិសដៅចម្បងសម្រាប់ឆ្នាំ២០១៦** ........ 26

IV. **សេចក្តីសន្និដ្ឋាន** ........ 28

## I. សេចក្តីផ្តើម

ផែនការអនុវត្តបីឆ្នាំដំណាក់កាលទី២(ផអ៣ទី២)នៃកម្មវិធីជាតិ ត្រូវបានអនុម័តដោយ គ.ជ.អ.ប នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤។ ផអ៣ទី២នេះត្រូវបានរៀបចំឡើងដោយផ្អែកលើភាពជោគជ័យ បញ្ហាប្រឈម និងបទពិសោធន៍នានានៃការអនុវត្តផអ៣ទី១។ ផអ៣ទី២បានកំណត់នូវសមិទ្ធផលរំពឹងទុកសំខាន់ៗចំនួន៥ ដែលត្រូវសម្រេចឱ្យបាននៅក្នុងរយៈពេល៣ឆ្នាំ គឺពីឆ្នាំ២០១៥ដល់ឆ្នាំ២០១៧។ សមិទ្ធផលរំពឹងទុកទាំងនោះ រួមមាន ១.)ការលើកកម្ពស់ការគ្រប់គ្រងកិច្ចដំណើរការកំណែទម្រង់ ២).ការបន្តធ្វើឱ្យមានភាពកាន់ល្អប្រសើរឡើងនូវការងារគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ៣.)ការបន្តលើកកម្ពស់ស្វ័យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងបុគ្គលិកនិងការអភិវឌ្ឍធនធានមនុស្ស ៤.) ការបន្តជំរុញការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវានិងការអភិវឌ្ឍមូលដ្ឋាន និង៥.) ការបន្តជំរុញការធ្វើវិមជ្ឈការហិរញ្ញវត្ថុ។ ដើម្បីធានាដល់ការសម្រេចបាននូវសមិទ្ធផលរំពឹងទុកទាំង៥ខាងលើ ផអ៣ទី២ក៏បានកំណត់នូវយុទ្ធសាស្ត្រ ឬសកម្មភាពជាអាទិភាពចំនួន១០៦ដែលត្រូវអនុវត្តដោយក្រសួង ស្ថាប័ននៅថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធនានា។

ផ្អែកលើមូលដ្ឋាននេះ ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥របស់ គ.ជ.អ.ប បានរៀបចំឡើងដោយកំណត់យកចំណុចដៅជាអាទិភាពចម្បងៗចំនួន**២០**សម្រាប់រៀបចំ និងដាក់ឱ្យអនុវត្តនៅតាមក្រសួងស្ថាប័ននៅថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធនានា ដើម្បីធានាដល់ការចូលរួមសម្រេចបាននូវសមិទ្ធផលរំពឹងទុកនីមួយៗនៃផអ៣ទី២ ដែលក្នុងនោះរួមមាន៖

- សមិទ្ធផលរំពឹងទុកទី១ មានចំណុចដៅជាអាទិភាពចំនួន**៣**
- សមិទ្ធផលរំពឹងទុកទី២ មានចំណុចដៅជាអាទិភាពចំនួន**៦**
- សមិទ្ធផលរំពឹងទុកទី៣ មានចំណុចដៅជាអាទិភាពចំនួន**៣**
- សមិទ្ធផលរំពឹងទុកទី៤ មានចំណុចដៅជាអាទិភាពចំនួន**៣** និង
- សមិទ្ធផលរំពឹងទុកទី៥ មានចំណុចដៅជាអាទិភាពចំនួន**៥**។

ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៥របស់គ.ជ.អ.ប ក៏បានកំណត់នូវសូចនាករជាក់លាក់នានាសម្រាប់ធ្វើជាមូលដ្ឋានក្នុងការតាមដាន ការត្រួតពិនិត្យ និងការវាស់វែងស្ថានភាពនៃការសម្រេចបាននូវចំណុចដៅជាអាទិភាពទាំង២០ខាងលើ ក៏ដូចជាសម្រាប់ធ្វើជាមូលដ្ឋានក្នុងការចាត់វិធានការដើម្បីការដោះស្រាយបញ្ហាប្រឈមនានាដែលកើតមានឡើងក្នុងពេលអនុវត្ត។

របាយការណ៍ប្រចាំឆ្នាំស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥ របស់ គ.ជ.អ.ប នេះ ផ្តោតជាសំខាន់ទៅលើស្ថានភាពនៃការអនុវត្តចំណុចដៅជាអាទិភាពនីមួយៗខាងលើដោយធ្វើការប្រៀបធៀបនូវវឌ្ឍនភាពដែលសម្រេចបានជាមួយនឹងសូចនាករនៃចំណុចដៅដែលបានកំណត់ ព្រមទាំងកំណត់នូវបញ្ហាប្រឈមជាគន្លឹះដែលជាឧបសគ្គក្នុងការសម្រេចបាននូវចំណុចដៅទាំងនោះ និងលើកឡើងនូវដំណោះស្រាយនានាដែលត្រូវផ្តោតការយកចិត្តទុកដាក់អនុវត្តនៅក្នុងឆ្នាំ២០១៦ ដើម្បីធានាដល់ការសម្រេចបានជាស្ថាពរនូវសមិទ្ធផលរពឹងទុកនានាដែលបានកំណត់នៅក្នុងផអ៣ទី២។

## II. វឌ្ឍនភាព បញ្ហាប្រឈម ការវិភាគ និងដំណោះស្រាយ

ផ្នែកនេះពិពណ៌នាអំពីស្ថានភាពនៃការអនុវត្តចំណុចដៅជាអាទិភាពទាំង២០ ដែលបានកំណត់ក្នុងផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥ របស់ គ.ជ.អ.ប ដោយធ្វើការប្រៀបធៀបវឌ្ឍនភាពដែលសម្រេចបានជាមួយនឹងសូចនាករដែលបានកំណត់ គូសបញ្ជាក់នូវបញ្ហាប្រឈមជាគន្លឹះដែលបានជួបប្រទះក្នុងពេលអនុវត្ត ព្រមទាំងធ្វើការវិភាគនូវស្ថានភាព និងហានិភ័យដែលអាចកើតមានឡើង ព្រមទាំងលើកឡើងនូវវិធានការនានាដែលត្រូវផ្តោតការយកចិត្តទុកដាក់ដោះស្រាយ និងបន្តអនុវត្តនៅក្នុងឆ្នាំ២០១៦ខាងមុខ។

### ១. ការគ្រប់គ្រងកិច្ចដំណើរការកំណែទម្រង់

#### ១.១. ចំណុចដៅជាអាទិភាពភាព

ជោគជ័យនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិក្នុងផអ៣ទី២គឺអាស្រ័យទៅលើប្រសិទ្ធភាពនៃការដឹកនាំ ការសម្របសម្រួល និងការគ្រប់គ្រងកិច្ចដំណើរការកំណែទម្រង់។ ដើម្បីធានាលើកកម្ពស់ប្រសិទ្ធភាពក្នុងការដឹកនាំ ការសម្របសម្រួល និងការគ្រប់គ្រងកិច្ចដំណើរការកំណែទម្រង់ក្នុងដំណាក់កាលនៃផអ៣ទី២នេះ ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥របស់ គ.ជ.អ.ប បានផ្តោតទៅលើចំណុចដៅជាអាទិភាពចំនួន**៣** ដូចខាងក្រោម៖

- ***ការពង្រឹងប្រសិទ្ធភាពនៃការរៀបចំកិច្ចប្រជុំរបស់ គ.ជ.អ.ប និងអនុគណៈកម្មាធិការនានានៃ គ.ជ.អ.ប*** ដោយផ្តោតលើការពិនិត្យ និងការពិគ្រោះយោបល់ដើម្បីស្វែងរកការឯកភាពគ្នាលើរបៀបវារៈ និងចំណុចដៅផ្នែកគោលនយោបាយសម្រាប់ជំរុញកិច្ចដំណើរការកំណែទម្រង់ឱ្យមានការវិវត្តទៅមុខបន្តទៀតស្របតាមក្របខណ្ឌពេលវេលា និងគោលដៅដែលបានកំណត់ ព្រមទាំងដើម្បីធានាឱ្យមានភាពស៊ីសង្វាក់គ្នាជាមួយនឹងការវិវត្តនៃកម្មវិធីកំណែទម្រង់ដទៃទៀតរបស់រាជរដ្ឋាភិបាល ជាពិសេសកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ទន្ទឹមគ្នានេះ កិច្ចប្រជុំរបស់ គ.ជ.អ.ប និងកិច្ចប្រជុំរបស់អនុគណៈកម្មាធិការនានានៃ គ.ជ.អ.ប ក៏ត្រូវផ្តោតទៅលើការគ្រប់គ្រង និងការតាមដានត្រួតពិនិត្យលើការអនុវត្តការងារកំណែទម្រង់ទាំងនៅក្នុងក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

សូចនាករសំខាន់ៗសម្រាប់វាស់វែងស្ថានភាពនៃការសម្រេចបាននូវចំណុចដៅជាអាទិភាពនេះ គឺការរៀបចំកិច្ចប្រជុំ គ.ជ.អ.ប ឱ្យបានចំនួនយ៉ាងតិច៣ដងក្នុងឆ្នាំ២០១៥នេះ។

- ***ការរៀបចំ និងដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រទំនាក់ទំនងព័ត៌មាន*** ដោយផ្តោតទៅលើការបន្តពង្រឹងប្រសិទ្ធភាពនៃការចែករំលែកព័ត៌មានក្នុងចំណោមស្ថាប័នរដ្ឋ និងជាមួយសាធារណជនតាមវិធីសាស្ត្រសមស្របនានា ក្នុងបំណងផ្តល់នូវព័ត៌មានសំខាន់ៗស្តីពីកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឱ្យបានកាន់តែច្បាស់លាស់ និងកាន់តែទូលំទូលាយ។

សូចនាករសំខាន់ៗសម្រាប់វាស់វែងស្ថានភាពនៃការសម្រេចបានចំណុចដៅជាអាទិភាពនេះ គឺការរៀបចំនូវសេចក្តីព្រាងយុទ្ធសាស្ត្រទំនាក់ទំនងស្តីពីការចែករំលែកព័ត៌មាន ការរៀបចំឱ្យមានព្រឹត្តិការណ៍សិក្សារៀនសូត្រយ៉ាងតិចចំនួន៣លើកតាមរយៈយុទ្ធសាស្ត្រទំនាក់ទំនងព័ត៌មាននេះ ដើម្បីស្វែងយល់ពីបទ

ពិសោធន៍នៃការអនុវត្តជាក់ស្តែងនៅតាមមូលដ្ឋាន ព្រមទាំងដើម្បីស្តាប់ និងដោះស្រាយបញ្ហាប្រឈមនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការរៀបចំយុទ្ធនាការផ្សព្វផ្សាយព័ត៌មានផ្នែកសង្គមដល់ប្រជាពលរដ្ឋឱ្យបានយ៉ាងតិចចំនួន១០០.០០០នាក់ ដើម្បីលើកកម្ពស់ការផ្លាស់ប្តូរឥរិយាបទក្នុងការទទួលខុសត្រូវ និងចូលរួមចំណែកក្នុងកិច្ចដំណើរការកំណែទម្រង់។

• ***ការពិនិត្យ និងកែសម្រួលនីតិវិធីនានារបស់លេខាធិការដ្ឋាន គ.ជ.អ.ប*** ដោយផ្តោតទៅលើការពិនិត្យកែសម្រួលនីតិវិធីអនុវត្តការងាររបស់លេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីធានាលើកកម្ពស់ប្រសិទ្ធភាពក្នុងការសម្របសម្រួល និងផ្តល់ការគាំទ្រដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការចូលរួមអនុវត្តកម្មវិធីកំណែទម្រង់ប្រកបដោយភាពជាម្ចាស់ និងការទទួលខុសត្រូវ។

សូចនាករសំខាន់ៗសម្រាប់វាស់វែងស្ថានភាពនៃការសម្រេចបានចំណុចដៅជាអាទិភាពនេះ គឺការពិនិត្យកែសម្រួលនិងការដាក់ឱ្យអនុវត្តនូវសៀវភៅណែនាំស្តីពីនីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ការរៀបចំសេចក្តីណែនាំស្តីពីកិច្ចដំណើរការរៀបចំគោលនយោបាយដើម្បីធានាដល់ការចូលរួម និងពង្រឹងភាពជាម្ចាស់របស់ក្រសួង ស្ថាប័ន ការពិនិត្យកែសម្រួលរចនាសម្ព័ន្ធរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ការកែសម្រួលតួនាទី និងភារកិច្ចរបស់មន្ត្រី បុគ្គលិក និងទីប្រឹក្សាបច្ចេកទេសដែលបំពេញការងារទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការពង្រឹងកិច្ចប្រជុំ និងវិធីសាស្ត្រទំនាក់ទំនងរបស់លេខាធិការដ្ឋាន គ.ជ.អ.ប និងការពិនិត្យកែសម្រួលកិច្ចដំណើរការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.បឱ្យមានលក្ខណៈសាមញ្ញ ព្រមទាំងលើកកម្ពស់ការចូលរួមពីអ្នកពាក់ព័ន្ធនានា ពិសេសថ្នាក់ដឹកនាំសំខាន់ៗ ហើយក៏ជាកិច្ចដំណើរការរៀបចំផែនការសកម្មភាពដែលផ្អែកលើលទ្ធផល។

## ១.២. វឌ្ឍនភាព

ក្នុងឆ្នាំ២០១៥នេះ សកម្មភាពជាអាទិភាពដែលបានកំណត់ខាងលើ ត្រូវបានចាប់ផ្តើមអនុវត្តដោយមានភាពយឺតយ៉ាវជាងការគ្រោងទុក។ ភាពយឺតយ៉ាវនេះ បណ្តាលមកពីការរៀបចំ ការអនុម័ត និងការដាក់ឱ្យអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៥របស់ គ.ជ.អ.ប ដែលជាឆ្នាំទី១នៃការអនុវត្តជអ៣ទី២ បានអូសបន្លាយពេលវេលារហូតដល់ខែមីនា ឆ្នាំ២០១៥។ អាស្រ័យហេតុនេះ ការអនុវត្តក្នុងឆ្នាំ២០១៥នេះ សម្រេចបានតាមសូចនាករនៃចំណុចដៅតែមួយចំនួនប៉ុណ្ណោះ។ ស្ថានភាពនៃការអនុវត្ត និងការសម្រេចបាននូវសូចនាករនៃចំណុចដៅជាអាទិភាពទាំង៣ដូចបានគូសបញ្ជាក់ខាងលើ រួមមានសង្ខេបដូចខាងក្រោម៖

### ការពង្រឹងប្រសិទ្ធភាពនៃការរៀបចំកិច្ចប្រជុំរបស់ គ.ជ.អ.ប និងអនុគណៈកម្មាធិការនានានៃ គ.ជ.អ.ប

ក្នុងឆ្នាំ២០១៥នេះ កិច្ចប្រជុំ របស់ គ.ជ.អ.ប និងកិច្ចប្រជុំរបស់អនុគណៈកម្មាធិការមួយចំនួននៃ គ.ជ.អ.ប ពុំត្រូវបានរៀបចំតាមពេលវេលាដែលបានកំណត់ឡើយ។ ការពន្យារពេលនៃការរៀបចំកិច្ចប្រជុំ គ.ជ.អ.ប និងកិច្ចប្រជុំរបស់អនុគណៈកម្មាធិការមួយចំនួនរបស់ គ.ជ.អ.ប នេះ ដោយសារមូលហេតុនៃការយឺតយ៉ាវក្នុងការរៀបចំបែបផែននានាសម្រាប់ការចាប់ផ្តើមអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៥របស់ គ.ជ.អ.ប នៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ មូលហេតុ

ចម្បងមួយផ្សេងទៀតនៃការពន្យារពេលរៀបចំកិច្ចប្រជុំ គ.ជ.អ.ប ក្នុងឆ្នាំ២០១៥នេះ គឺមានភាពយឺតយ៉ាវនៃការរៀបចំលិខិតបទដ្ឋានគតិយុត្តចាំបាច់មួយចំនួនដែលត្រូវដាក់ជូនកិច្ចប្រជុំ គ.ជ.អ.ប ពិនិត្យ ពិភាក្សា ធ្វើការសម្រេចចិត្តផ្នែកនយោបាយ និងផ្តល់គោលការណ៍តម្រង់ទិសជាយុទ្ធសាស្ត្រនានា។ ការរៀបចំឯកសារគតិយុត្តទាំងនោះទាមទារនូវពេលវេលាសមស្របសម្រាប់សិក្សាស្រាវជ្រាវ វិភាគ និងពិភាក្សាក្នុងចំណោមមន្ត្រីដឹកនាំកម្រិតបច្ចេកទេសតាមក្រសួង ស្ថាប័នទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានាផ្សេងទៀតផងដែរ។ ទោះជាយ៉ាងនេះក្តី លេខាធិការដ្ឋាន គ.ជ.អ.ប បានសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានាក្នុងរៀបចំឯកសារទាំងនោះរួចរាល់ហើយ សម្រាប់ត្រៀមរៀបចំកិច្ចប្រជុំ គ.ជ.អ.ប នៅដើមឆ្នាំ២០១៦ ដោយផ្តោតជាសំខាន់ទៅលើរបៀបវារៈដែលពាក់ព័ន្ធនឹងការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ ការរៀបចំ និងដាក់ចេញនូវលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ កិច្ចការនានាពាក់ព័ន្ធនឹងការវិវត្តនៃវិមជ្ឈការហិរញ្ញវត្ថុ ការពិនិត្យលើលទ្ធផលនិងបញ្ហាប្រឈមនៃការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៥ ព្រមទាំងការពិនិត្យ ពិភាក្សា និងការអនុម័តលើផែនការសកម្មភាព និងថវិកាឆ្នាំ២០១៦របស់ គ.ជ.អ.ប។

**ការរៀបចំ និងដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រទំនាក់ទំនងព័ត៌មាន**

នៅក្នុងឆ្នាំ២០១៥នេះ ដោយមានការគាំទ្រផ្នែកបច្ចេកទេសពីអង្គការមូលនិធិអាស៊ី លេខាធិការដ្ឋាន គ.ជ.អ.ប បានសិក្សា និងរៀបចំនូវសេចក្តីព្រាងបឋមនៃយុទ្ធសាស្ត្រទំនាក់ទំនងព័ត៌មាននេះ ដើម្បីត្រៀមដាក់ឱ្យមានការពិភាក្សា ពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មុននឹងអនុម័ត និងដាក់ឱ្យអនុវត្តនៅក្នុងឆ្នាំ២០១៦ខាងមុខនេះ។

**ការពិនិត្យ និងកែសម្រួលនីតិវិធីនានារបស់លេខាធិការដ្ឋាន គ.ជ.អ.ប**

លេខាធិការដ្ឋានគ.ជ.អ.ប បានសិក្សា និងកែសម្រួលជាបណ្តើរៗនូវសៀវភៅណែនាំស្តីពីប្រតិបត្តិការរដ្ឋបាល និងនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុរបស់ គ.ជ.អ.ប ឱ្យមានលក្ខណៈកាន់តែល្អប្រសើរ និងកាន់តែមានការជឿទុកចិត្តពីសំណាក់ដៃគូអភិវឌ្ឍន៍នានា។ សេចក្តីព្រាងបឋមនៃសេចក្តីណែនាំស្តីពីនីតិវិធីរៀបចំគោលនយោបាយក៏ត្រូវបានរៀបចំ និងកំពុងដាក់ឱ្យមានការពិភាក្សា ពិគ្រោះយោបល់ផ្ទៃក្នុងលេខាធិការដ្ឋាន គ.ជ.អ.ប ផងដែរ។ ទន្ទឹមគ្នានេះ លេខាធិការដ្ឋានគ.ជ.អ.ប ក៏បានសិក្សាវាយតម្លៃអំពីស្ថានភាពអនុវត្តការងាររបស់មន្ត្រី និងទីប្រឹក្សាបច្ចេកទេសដែលកំពុងបំពេញការងារទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងបានពិនិត្យកែសម្រួលតួនាទី ភារកិច្ចរបស់មន្ត្រី និងទីប្រឹក្សាបច្ចេកទេសទាំងនោះ ព្រមទាំងបានរៀបចំផែនការបុគ្គលិកសម្រាប់ឆ្នាំ២០១៦ ដើម្បីឆ្លើយតបទៅនឹងតម្រូវការងារជាក់ស្តែង និងតម្រូវការនៃការកាត់បន្ថយជំនួយបច្ចេកទេសជាបណ្តើរៗពីឆ្នាំ២០១៦តទៅ។ ជាមួយគ្នានេះដែរ ដើម្បីតាមដានត្រួតពិនិត្យ ផ្តល់ការសម្របសម្រួល និងការគាំទ្រដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៥របស់ គ.ជ.អ.ប លេខាធិការដ្ឋាន គ.ជ.អ.ប បានរៀបចំកិច្ចប្រជុំចំនួន៣លើកជាមួយតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងជាមួយតំណាងរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។ វិធីសាស្ត្រក្នុងការរៀបចំកិច្ចប្រជុំទាំងនេះ ក៏បានកែលំអ ដោយលេខាធិការដ្ឋាន គ.ជ.អ.ប បានប្រមូលនូវ

ទិន្នន័យ និងព័ត៌មានពាក់ព័ន្ធនានារួចជាស្រេចនៅមុនពេលកិច្ចប្រជុំ ហើយក្នុងកិច្ចប្រជុំបានផ្តោតសំខាន់ទៅលើការពិនិត្យ ការពិភាក្សាអំពីបញ្ហាប្រឈម និងដំណោះស្រាយនានាដែលត្រូវចាត់វិធានការអនុវត្តឱ្យបានទាន់ពេលវេលា។

### ១.៣. បញ្ហាប្រឈម

ទោះបីជា លេខាធិការដ្ឋាន គ.ជ.អ.ប បានខិតខំប្រឹងប្រែង និងបានពង្រឹងប្រសិទ្ធភាពការអនុវត្តតួនាទីជាសេនាធិការរបស់ គ.ជ.អ.ប ក្នុងការសម្របសម្រួល និងការគាំទ្រផ្នែកបច្ចេកទេសដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៥ ឱ្យមានដំណើរការដោយរលូនក្តី ក៏ប៉ុន្តែបើប្រៀបធៀបទៅនឹងសូចនាករនៃចំណុចដៅដែលបានកំណត់ យើងអាចវាយតម្លៃបានថា ស្ថានភាពនៃការអនុវត្តក្នុងឆ្នាំ២០១៥នេះ ពុំទាន់បានសម្រេចទាំងស្រុងដូចការរំពឹងទុកឡើយ។ សូចនាករសំខាន់ដែលពុំទាន់បានសម្រេច គឺការខកខាន ឬការពន្យារពេលនៃការរៀបចំកិច្ចប្រជុំរបស់គ.ជ.អ.ប និងកិច្ចប្រជុំរបស់អនុគណៈកម្មាធិការនានានៃគ.ជ.អ.ប។ ភាពយឺតយ៉ាវនៃការរៀបចំ និងដាក់ឱ្យអនុវត្តនូវផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៥ និងភាពយឺតយ៉ាវនៃការរៀបចំឯកសារគតិយុត្តពាក់ព័ន្ធនានាសម្រាប់ដាក់ជូនកិច្ចប្រជុំ គ.ជ.អ.ប ពិនិត្យ ពិភាក្សា ដើម្បីធ្វើការសម្រេចចិត្តផ្នែកនយោបាយ គឺជាកត្តាចម្បងដែលបណ្តាលឱ្យមានការខកខាន ឬការពន្យារពេលនៃការរៀបចំកិច្ចប្រជុំ គ.ជ.អ.ប និងកិច្ចប្រជុំរបស់អនុគណៈកម្មាធិការនានានៃ គ.ជ.អ.ប នៅក្នុងឆ្នាំ២០១៥នេះ។

### ១.៤. ការវិភាគ និងដំណោះស្រាយ

ការខកខាន ឬការពន្យារពេលនៃការរៀបចំកិច្ចប្រជុំរបស់ អនុគណៈកម្មាធិការនានានៃ គ.ជ.អ.ប និងកិច្ចប្រជុំរបស់ គ.ជ.អ.ប អាចជាឧបសគ្គដ៏ចម្បងមួយក្នុងការសម្រេចបាននូវសូចនាករនានាដែលបានកំណត់ក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៥របស់ គ.ជ.អ.ប ក៏ដូចជាឧបសគ្គក្នុងការសម្រេចបាននូវសមិទ្ធផលរំពឹងនៃផអ៣ទី២ផងដែរ។ ការសម្រេចចិត្តផ្នែកនយោបាយ និងការផ្តល់គោលការណ៍តម្រង់ទិសជាយុទ្ធសាស្ត្រនានា របស់ គ.ជ.អ.ប អំពីការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ អំពីការរៀបចំយន្តការផ្ទេរមូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់អនុវត្តនូវមុខងារដែលបានផ្ទេរ អំពីការកែលំអប្រព័ន្ធនិងនីតិវិធីគ្រប់គ្រងមូលនិធិគ្មានភ្ជាប់ល័ក្ខខ័ណ្ឌរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ អំពីការបង្កើតប្រព័ន្ធគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអំពីការពង្រឹងភាពជាម្ចាស់ និងការចូលរួមរបស់ក្រសួង ស្ថាប័នទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងកិច្ចដំណើរការកំណែទម្រង់ **គឺជាកិច្ចការដ៏សំខាន់ និងចាំបាច់ដែលបានកំណត់ក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៥របស់ គ.ជ.អ.ប ហើយក៏ជាកិច្ចការដែលត្រូវមានការសម្រេចចិត្តផ្នែកនយោបាយ នៅក្នុងឆ្នាំ២០១៥នេះផងដែរ**។ ក្នុងន័យនេះ ការខកខាន ឬការពន្យារពេលនៃការរៀបចំកិច្ចប្រជុំ គ.ជ.អ.ប ដើម្បីពិនិត្យ សម្រេចលើកិច្ចការខាងលើនឹងធ្វើឱ្យមានភាពយឺតយ៉ាវក្នុងការចាត់វិធានការអនុវត្តសកម្មភាពពាក់ព័ន្ធនានារបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រការនេះនឹងធ្វើឱ្យមានភាពយឺតយ៉ាវក្នុងការសម្រេចបាននូវសមិទ្ធផលរំពឹងទុកនានាដែលបានកំណត់ក្នុងផអ៣ទី២ ក៏ដូចជាកម្មវិធីកំណែទម្រង់ទាំងមូល។

ដើម្បីធានាដោះស្រាយបញ្ហាប្រឈមខាងលើ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវបន្ថែមការខិតខំប្រឹងប្រែងសម្របសម្រួល គាំទ្រ និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំឯកសារ និងកិច្ចការចាំបាច់នានា ដើម្បីរៀបចំកិច្ចប្រជុំ គ.ជ.អ.ប ឱ្យបានយ៉ាងយូរនៅដើមឆ្នាំ ២០១៦ខាងមុខនេះ។

ជាមួយគ្នានេះដែរ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវបន្តការសម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានាដើម្បីធ្វើបច្ចុប្បន្នភាពសមាជិកភាពនៃអនុគណៈកម្មាធិការនានារបស់ គ.ជ.អ.ប និងត្រូវបង្កើនការគាំទ្រដល់អនុគណៈកម្មាធិការទាំងនោះ ដើម្បីធានាឱ្យអនុគណៈកម្មាធិការទាំងនោះមានផែនការការងារច្បាស់លាស់ និងរៀបចំកិច្ចប្រជុំឱ្យបានទៀងទាត់ ព្រមទាំងត្រូវមានរបាយការណ៍ជាក់លាក់សម្រាប់រាយការណ៍ជូន គ.ជ.អ.ប ផងដែរ។

# ២. គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ

## ២.១. ចំណុចដៅជាអាទិភាពភាព

ការបន្តអភិវឌ្ឍរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យក្លាយជាស្ថាប័នប្រជាធិបតេយ្យ តំណាងយ៉ាងពិតប្រាកដរបស់ប្រជាពលរដ្ឋ និងមានលទ្ធភាពក្នុងការឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពនានារបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព គឺជាសមិទ្ធផលរំពឹងទុកដ៏សំខាន់មួយនៃផអ៣ទី២។ ដើម្បីធានាដល់ការសម្រេចបាននូវសមិទ្ធផលរំពឹងទុកនេះ ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ២០១៥របស់ គ.ជ.អ.ប បានកំណត់នូវចំណុចដៅជាអាទិភាពចំនួន**៦**ដែលត្រូវទទួលខុសត្រូវអនុវត្តដោយក្រសួង ស្ថាប័ននៅថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធនានា។ ចំណុចដៅជាអាទិភាពទាំង**៦នេះ** រួមមាន៖

- **ការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គម** ដោយផ្តោតទៅលើការបន្តពង្រឹងប្រសិទ្ធភាព និងគណនេយ្យភាពនៃការផ្តល់សេវារបស់រដ្ឋបាលថ្នាក់ក្រោមជាតិជូនប្រជាពលរដ្ឋ តាមរយៈការបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការទទួលបាននូវព័ត៌មានចាំបាច់នានាពាក់ព័ន្ធការផ្តល់សេវា ក៏ដូចជាការបង្កលក្ខណៈឱ្យប្រជាពលរដ្ឋចូលរួមតាមដានត្រួតពិនិត្យលើការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានរបស់រដ្ឋបាល ថ្នាក់ក្រោមជាតិក្នុងការអនុវត្តតួនាទីភារកិច្ច និងមុខងារតាមអាណត្តិរបស់ខ្លួន។

សូចនាករសំខាន់ៗដែលបានកំណត់សម្រាប់វាស់វែងស្ថានភាពនៃការអនុវត្តសកម្មភាពជាអាទិភាពនេះ គឺការរៀបចំ និងដាក់ឱ្យអនុវត្តនូវផែនការអនុវត្តរយៈពេល៣ឆ្នាំនៃផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គម ការរៀបចំបែបផែននានាសម្រាប់ការសម្របសម្រួល និងគ្រប់គ្រងការអនុវត្តផែនការអនុវត្តរយៈពេល៣ឆ្នាំខាងលើ ការរៀបចំសៀវភៅណែនាំស្តីពីកិច្ចប្រតិបត្តិការការងារគណនេយ្យភាពសង្គមសម្រាប់ផ្នែកផ្គត់ផ្គង់ ការអនុវត្តសកម្មភាពគណនេយ្យភាពសង្គមនៅតាមឃុំគោលដៅក្នុងស្រុកចំនួន២២ និងការប្រមូលចងក្រងទិន្នន័យដើមគ្រាសម្រាប់ការវាស់វែងអំពីផលប៉ះពាល់នៃការងារគណនេយ្យភាពសង្គម។

- **ការរៀបចំ និងអនុវត្តវិធានគ្រប់គ្រងផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុក** ផ្តោតលើការបន្តពង្រឹងប្រសិទ្ធភាពនៃការ

គ្រប់គ្រងរដ្ឋបាលក្រុង ស្រុក ស្របតាមគោលការណ៍អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ។ រដ្ឋបាល ក្រុង ស្រុកនីមួយៗត្រូវរៀបចំវិធានគ្រប់គ្រងផ្ទៃក្នុងដើម្បីកំណត់នូវគោលការណ៍គ្រប់គ្រងសំខាន់ៗ ការបែងចែកសិទ្ធិអំណាច និងតួនាទីភារកិច្ចក្នុងចំណោមក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីតាមអង្គភាពនានានៃរដ្ឋបាលក្រុង ស្រុក ព្រមទាំងកំណត់នូវខ្សែគណនេយ្យភាពផ្ទៃក្នុងរដ្ឋបាលក្រុង ស្រុក និងយន្តការគណនេយ្យភាពរបស់រដ្ឋបាលក្រុង ស្រុកជាមួយប្រជាពលរដ្ឋក្នុងការផ្តល់សេវា និងកិច្ចអភិវឌ្ឍមូលដ្ឋានរបស់ខ្លួន។ វិធានគ្រប់គ្រងផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុក គឺជាក្របខណ្ឌគតិយុត្តចម្បងរបស់រដ្ឋបាលក្រុង ស្រុកនីមួយៗ ដែលត្រូវរៀបចំឡើងដោយមានការចូលរួមយ៉ាងទូលំទូលាយពីសំណាក់អ្នកពាក់ព័ន្ធនានា ព្រមទាំងមានការឯកភាព និងអនុម័តដោយក្រុមប្រឹក្សានៃរដ្ឋបាលក្រុង ស្រុកសាមីនីមួយៗ។

សូចនាករសំខាន់ៗសម្រាប់វាស់វែងស្ថានភាពនៃការសម្រេចបាននូវចំណុចដៅជាអាទិភាពនេះ គឺការរៀបចំ និងផ្សព្វផ្សាយសេចក្តីណែនាំ និងគំរូដីកាស្តីពីវិធានគ្រប់គ្រងផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាល ក្រុង ស្រុកយ៉ាងតិចចំនួន៥០បានរៀបចំ អនុម័ត និងដាក់ឱ្យអនុវត្តនូវដីកាស្តីពីវិធានគ្រប់ផ្ទៃក្នុងរបស់ខ្លួននៅក្នុងឆ្នាំ២០១៥នេះ។

• **ការរៀបចំ និងដាក់ឱ្យអនុវត្តនូវប្រព័ន្ធអធិការកិច្ចលើការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** ផ្តោតទៅលើការរៀបចំធ្វើអធិការកិច្ចលើការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសលើការអនុវត្តការងាររបស់រដ្ឋបាលក្រុង ស្រុក ដើម្បីធានាថា រដ្ឋបាលថ្នាក់ក្រុង ស្រុកបានគ្រប់គ្រង ចាត់ចែង អនុវត្តតួនាទី ភារកិច្ច មុខងារ និងធនធាននានាស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត ប្រព័ន្ធ នីតិវិធី និងស្តង់ដារដែលបានកំណត់។

សូចនាករសំខាន់ៗសម្រាប់វាស់វែងស្ថានភាពនៃការសម្រេចបាននូវចំណុចដៅជាអាទិភាពនេះ គឺការរៀបចំ និងអនុម័តនូវយុទ្ធសាស្ត្រសម្រាប់ការធ្វើអធិការកិច្ច ការរៀបចំសៀវភៅណែនាំស្តីពីការធ្វើអធិការកិច្ច ការធ្វើអធិការកិច្ចទៅលើរដ្ឋបាលក្រុង ស្រុកមួយចំនួន និងការរៀបចំនិងការអនុម័តផែនការអធិការកិច្ចសម្រាប់ឆ្នាំ២០១៦។

• **ការពង្រឹងសមត្ថភាពសមាគមជាតិនៃក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ** ដោយផ្តោតទៅលើកកម្ពស់ការផ្តល់សេវាជូនសមាជិកនៃសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានសមាគមក្រុមប្រឹក្សារាជធានី ខេត្ត និងសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ប្រកបដោយប្រសិទ្ធភាព ព្រមទាំងជំរុញដល់ការចូលរួមក្នុងនាមជាតំណាងសម្លេង និងផលប្រយោជន៍របស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងកិច្ចដំណើរការរៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល។

សូចនាករសំខាន់ៗសម្រាប់វាស់វែងស្ថានភាពនៃការសម្រេចបាននូវអាទិភាពនេះ គឺការពិនិត្យកែសម្រួលរចនាសម្ព័ន្ធនៃអគ្គលេខាធិការដ្ឋានរបស់សមាគមជាតិនៃក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ និងការរៀបចំ និងការដាក់ចេញនូវយុទ្ធសាស្ត្រផ្តល់សេវា និងការបង្កើនចំណូលសមាជិកភាពរបស់សមាគមជាតិនៃក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។

• **ការរៀបចំ និងដាក់ឱ្យអនុវត្តសៀវភៅណែនាំស្តីពីនីតិវិធីរដ្ឋបាលរាជធានីខេត្ត និងក្រុងស្រុកខណ្ឌ** ផ្តោតលើការ

បន្តរៀបចំ និងដាក់ឱ្យអនុវត្តនូវប្រព័ន្ធគ្រប់គ្រងកិច្ចការរដ្ឋបាលដែលមានលក្ខណៈស្តង់ដាររួមមួយនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងការពង្រឹងសមត្ថភាពគ្រប់គ្រង និងចាត់ចែងកិច្ចការរដ្ឋបាលរបស់មន្ត្រីនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌឱ្យកាន់តែមានប្រសិទ្ធភាព និងកាត់បន្ថយការិយាធិបតេយ្យ។

សូចនាករសំខាន់ៗសម្រាប់វាស់វែងស្ថានភាពនៃការសម្រេចបាននូវចំណុចដៅជាអាទិភាពនេះ គឺការរៀបចំ និងដាក់ឱ្យអនុវត្តសៀវភៅណែនាំស្តីពីនីតិវិធីរដ្ឋបាល និងការរៀបចំវគ្គបណ្តុះបណ្តាលអំពីសៀវភៅណែនាំនេះដល់មន្ត្រីពាក់ព័ន្ធនានានៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

• **ការរៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រង** ផ្តោតទៅលើការបង្កើត និងដាក់ឱ្យអនុវត្តនូវប្រព័ន្ធត្រួតពិនិត្យវាយតម្លៃរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមប្រព័ន្ធកុំព្យូទ័រសម្រាប់ផ្តល់ និងទទួលព័ត៌មានសំខាន់ៗសម្រាប់កិច្ចប្រជុំក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ព្រមទាំងសម្រាប់ផ្សព្វផ្សាយព័ត៌មានជូនប្រជាពលរដ្ឋ និងទទួលព័ត៌មានត្រឡប់ពីប្រជាពលរដ្ឋវិញផងដែរ។ ប្រព័ន្ធត្រួតពិនិត្យវាយតម្លៃនេះ ក៏អាចប្រើប្រាស់សម្រាប់ការប្រមូលនូវធាតុចូល និងផ្តល់ព័ត៌មាននានាមកថ្នាក់ជាតិអំពីស្ថានភាពការងារ និងបញ្ហាប្រឈមនានាដែលកើតមានឡើងនៅតាមមូលដ្ឋាននៃរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ។

សូចនាករសំខាន់ៗសម្រាប់វាស់វែងស្ថានភាពនៃការសម្រេចបាននូវចំណុចដៅអាទិភាពនេះ គឺការរៀបចំបង្កើតប្រព័ន្ធព័ត៌មានគំរូមួយសម្រាប់ការគ្រប់គ្រងនៅថ្នាក់ក្រុង ស្រុក ខណ្ឌ ការអនុវត្តសាកល្បងនូវប្រព័ន្ធគំរូនេះ និងការប្រើប្រាស់នូវព័ត៌មានដែលប្រមូលបានពីការអនុវត្តប្រព័ន្ធនេះសម្រាប់កិច្ចប្រជុំក្រុមប្រឹក្សា ក្រុងស្រុកចំនួនយ៉ាងតិច១០០កិច្ចប្រជុំ។

## ២.២. វឌ្ឍនភាព

ក្នុងឆ្នាំ២០១៥នេះ ចំណុចដៅជាអាទិភាពនានាដែលបានកំណត់ខាងលើបានអនុវត្តជាបណ្តើរៗ និងសម្រេចបាននូវលទ្ធផលតាមសូចនាករដែលបានកំណត់ស្ទើរតែទាំងស្រុង។ ស្ថានភាពនៃការអនុវត្ត និងការសម្រេចបានតាមសូចនាករនៃចំណុចដៅជាអាទិភាពទាំងនោះ រួមមានសង្ខេបដូចខាងក្រោម៖

**ការអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីការងារគណនេយ្យភាពសង្គម**

លេខាធិការដ្ឋាន គ.ជ.អ.ប បានរៀបចំសេចក្តីព្រាងផែនការអនុវត្តរយៈពេល៣ឆ្នាំ ដោយមានការពិភាក្សាពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនានា ជាពិសេសជាមួយតំណាងដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល។ សេចក្តីព្រាងផែនការអនុវត្តរយៈពេល៣ឆ្នាំនេះ ត្រូវបានដាក់ជូនថ្នាក់ដឹកនាំលេខាធិការដ្ឋានពិនិត្យ និងអនុម័ត។ ទន្ទឹមគ្នានេះ ដើម្បីជានាដល់ការសម្របសម្រួល ណែនាំតម្រង់ទិស និងការតាមដានត្រួតពិនិត្យលើការអនុវត្តផែនការអនុវត្តរយៈពេល៣ឆ្នាំនេះ គ.ជ.អ.ប ក៏បានរៀបចំបង្កើតគណៈកម្មាធិការគ្រប់គ្រងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមមួយ ដែលមានសមាសភាពជាតំណាងមកពីលេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល។ ផ្អែកលើផែនការអនុវត្តរយៈពេល៣ឆ្នាំ ដោយសហកាជាមួយអង្គការសង្គមស៊ីវិលជាដៃគូ លេខាធិការដ្ឋាន គ.ជ.អ.ប ក៏បានរៀបចំសេចក្តីព្រាងបឋមនៃសៀវភៅណែនាំស្តីពីកិច្ចប្រតិបត្តិការការងារគណនេយ្យភាពសង្គមសម្រាប់ផ្នែកផ្គត់ផ្គង់ និងគ្រោងដាក់ឱ្យមានការពិនិត្យ ពិភាក្សា ពិគ្រោះយោបល់ និងដាក់ឱ្យប្រើប្រាស់នៅពី

ដើមឆ្នាំ២០១៦តទៅ។ លើសពីនេះ លេខាធិការដ្ឋាន គ.ជ.អ.ប ក៏បានសហការជាមួយអង្គការសង្គមស៊ីវិលជាដៃគូចំនួន**៥**ដើម្បីផ្ដល់ការសម្របសម្រួល និងការគាំទ្រផ្នែកបច្ចេកទេសដល់ស្រុកគោលដៅចំនួន**២៧** ដើម្បីបង្កលក្ខណៈឱ្យស្រុកគោលដៅទាំងនេះមានលទ្ធភាពក្នុងការចាប់ផ្ដើមអនុវត្តនូវផែនការសកម្មភាពការងារគណនេយ្យភាពរបស់ខ្លួនជាបណ្ដើរៗ នៅតាមឃុំនានាក្នុងស្រុករបស់ខ្លួន ដោយផ្ដោតជាបឋមទៅលើការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងសិទ្ធិរបស់ប្រជាពលរដ្ឋ និងស្តង់ដារនៃការផ្តល់សេវាក្នុងវិស័យសុខាភិបាល  វិស័យអប់រំ និងសេវារដ្ឋបាល ព្រមទាំងកិច្ចការអភិវឌ្ឍមូលដ្ឋាននៅតាមភូមិឃុំនានាផងដែរ។

**ការរៀបចំ និងអនុវត្តវិធានគ្រប់គ្រងផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុក**

វឌ្ឍនភាពជាចម្បងក្នុងការអនុវត្តចំណុចដៅជាអាទិភាពពាក់ព័ន្ធនឹងការរៀបចំវិធានគ្រប់គ្រងផ្ទៃក្នុងរបស់រដ្ឋបាលក្រុង ស្រុក ក្នុងឆ្នាំ២០១៥នេះ ក្រសួងមហាផ្ទៃ ដោយសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប បានរៀបចំបញ្ចប់ជាស្ថាពរនូវសេចក្តីណែនាំ និងគំរូដីកាស្តីពីវិធានគ្រប់គ្រងផ្ទៃក្នុងរបស់រដ្ឋបាល ក្រុង ស្រុក។ ក្រសួងមហាផ្ទៃក៏បានរៀបចំការផ្សព្វផ្សាយ និងរៀបចំវគ្គបណ្តុះបណ្តាលអំពីសេចក្តីណែនាំ និងគំរូដីកានេះដល់ក្រុមប្រឹក្សា និងមន្ត្រីនៃរដ្ឋបាលក្រុង ស្រុករួចរាល់ហើយផងដែរ។ ជាមួយគ្នានេះ នៅចុងឆ្នាំ២០១៥នេះ រដ្ឋបាលក្រុង ស្រុកទាំងអស់នៅទូទាំងប្រទេសក៏បានចាប់ផ្តើមដំណើរការរៀបចំ អនុម័តដីកាស្តីពីវិធានគ្រប់គ្រងផ្ទៃក្នុង ដែលក្នុងនោះមានក្រុង ស្រុកចំនួន៥៤ បានរៀបចំបញ្ចប់ អនុម័ត និងដាក់ឱ្យអនុវត្តនូវវិធានគ្រប់គ្រងផ្ទៃក្នុងរបស់ខ្លួនផងដែរ។

**ការរៀបចំ និងដាក់ឱ្យអនុវត្តនូវប្រព័ន្ធអធិការកិច្ចលើការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

ពាក់ព័ន្ធនឹងការរៀបចំប្រព័ន្ធធ្វើអធិការកិច្ចលើការអនុវត្តការងាររបស់រដ្ឋបាលក្រុង ស្រុក ក្នុងឆ្នាំ២០១៥នេះ ក្រសួងមហាផ្ទៃបានសិក្សា និងពិនិត្យឡើងវិញលើសេចក្តីព្រាងបឋមនៃក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់ការធ្វើអធិការកិច្ចដែលបានរៀបចំជាសេចក្តីព្រាងបឋមនៅក្នុងឆ្នាំ២០១៤។ ការពិភាក្សា និងពិគ្រោះយោបល់មានលក្ខណៈទូលំទូលាយជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិលើសេចក្តីព្រាងក្របខណ្ឌយុទ្ធសាស្ត្រនេះបានធ្វើឡើងនៅចុងឆ្នាំ២០១៥។ ផ្អែកលើក្របខណ្ឌយុទ្ធសាស្ត្រ ក្រសួងមហាផ្ទៃនឹងរៀបចំសៀវភៅណែនាំអំពីនីតិវិធីធ្វើអធិការកិច្ច ដើម្បីចាប់ផ្តើមអនុវត្តការធ្វើអធិការកិច្ចទៅលើការអនុវត្តការងាររបស់រដ្ឋបាលក្រុង ស្រុកមួយចំនួននៅពាក់កណ្តាលឆ្នាំ២០១៦។

**ការពង្រឹងសមត្ថភាពសមាគមជាតិនៃរដ្ឋបាលថ្នាក់ក្រោមជាតិ**

វឌ្ឍនភាពគួរឱ្យកត់សម្គាល់ពាក់ព័ន្ធនឹងការពង្រឹងសមត្ថភាពសមាគមជាតិនៃរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងឆ្នាំ២០១៥នេះ  គឺការបង្កើតបានជាស្ថាពរនូវសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នៅថ្នាក់រាជធានី ខេត្តទាំងអស់ ហើយសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នេះ បានរួមគ្នាបង្កើតជាសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ ជាមួយគ្នានេះដែរ ក្នុងឆ្នាំ២០១៥នេះ សម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងសមាគមជាតិក្រុមប្រឹក្សារាជធានី ខេត្ត ក៏បានឯកភាពគ្នាបង្កើតនូវអគ្គលេខាធិការដ្ឋានរួមមួយ ដើម្បីផ្តល់ការគាំទ្រ និងបម្រើផលប្រយោជន៍ដល់សមាគមទាំងពីរខាងលើនេះ។ រចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋានរួមនេះ ក៏ត្រូវបានពិនិត្យកែសម្រួលដើម្បី

ធានាដល់ការរៀបចំតួនាទី ការទទួលខុសត្រូវ និងផែនការយុទ្ធសាស្ត្រថ្មីសំដៅលើកកម្ពស់ប្រសិទ្ធភាពការងាររបស់ខ្លួន។ ក្រៅពីនេះ ផ្អែកលើយុទ្ធសាស្ត្រថ្មីនេះ អគ្គលេខាធិការដ្ឋាន ក៏បានខិតខំរៀបចំ និងដាក់ចេញនូវនីតិវិធីអនុវត្តការងាររបស់ខ្លួន ក្នុងនោះរួមមានសេចក្តីណែនាំអំពីគោលការណ៍ណែនាំរដ្ឋបាល និងហិរញ្ញវត្ថុ ក្រមសីលធម៌ព្រមទាំងបានបើកវគ្គបណ្តុះបណ្តាលផ្សេងៗផងដែរ។

**ការរៀបចំ និងដាក់ឱ្យអនុវត្តសៀវភៅណែនាំស្តីពីនីតិវិធីរដ្ឋបាលរាជធានីខេត្ត និងក្រុងស្រុកខណ្ឌ**

ពាក់ព័ន្ធនឹងការរៀបចំ និងដាក់ឱ្យអនុវត្តនូវសៀវភៅណែនាំស្តីពីនីតិវិធីរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងឆ្នាំ២០១៥នេះ ក្រសួងមហាផ្ទៃបានរៀបចំ អនុម័ត ដើម្បីដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំនេះរួចរាល់ជាស្ថាពរហើយ។ សៀវភៅណែនាំនេះផ្តោតជាសំខាន់ទៅលើនីតិវិធីរៀបចំលិខិតរដ្ឋបាល លិខិតបទដ្ឋានគតិយុត្ត ការងាររបៀប ការគ្រប់គ្រងសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ការគ្រប់គ្រងឯកសារ និងនីតិវិធីរៀបចំកិច្ចប្រជុំនានារបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ នៅចុងឆ្នាំ២០១៥នេះ ក្រសួងមហាផ្ទៃក៏បានរៀបចំវគ្គបណ្តុះបណ្តាលអំពីសៀវភៅណែនាំនេះដល់មន្ត្រីបង្គោលនានានៃមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត ដើម្បីឱ្យមណ្ឌលនេះមានលទ្ធភាពក្នុងការរៀបចំការបណ្តុះបណ្តាលបន្តដល់មន្ត្រីទាំងអស់នៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌចាប់ពីដើមឆ្នាំ២០១៦តទៅ។

**ការរៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រង**

ពាក់ព័ន្ធនឹងការរៀបចំប្រព័ន្ធព័ត៌មានសម្រាប់ការគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រុង ស្រុក ក្នុងឆ្នាំ២០១៥នេះ លេខាធិការដ្ឋាន គ.ជ.អ.ប បានរៀបចំសរសេរកម្មវិធីកុំព្យូទ័រស្តីពីប្រព័ន្ធតាមដាន និងវាយតម្លៃផ្ទៃក្នុងសម្រាប់ការគ្រប់គ្រងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ព្រមទាំងបានដាក់ឱ្យអនុវត្តសាកល្បងនៅតាម ក្រុង ស្រុក ខណ្ឌចំនួន១០។

## ២.៣. បញ្ហាប្រឈម

ជារួម ទោះបីមានការយឺតយ៉ាវក្នុងការចាប់ផ្តើមអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៥ របស់ គ.ជ.អ.ប ក៏ដោយ ក៏ចំណុចដៅជាអាទិភាពនានាដែលបានកំណត់នៅក្នុងសមិទ្ធផលរំពឹងទុកនេះត្រូវបានអនុវត្តជាបណ្តើរៗ និងសម្រេចបានតាមសូចនាករដែលបានកំណត់ស្ទើរតែទាំងស្រុង។

ទោះយ៉ាងនេះក្តី ក៏សូចនាករសំខាន់ដែលមិនទាន់បានសម្រេចតាមការគ្រោងទុក គឺការរៀបចំ និងការអនុម័តនូវក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់ការផ្ទេរអធិការកិច្ចលើការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ មូលហេតុចម្បងនៃការយឺតយ៉ាវក្នុងការសម្រេចបាននូវសូចនាករនេះ គឺដោយសារការរៀបចំប្រព័ន្ធអធិការកិច្ចក្រោមក្របខណ្ឌនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ជាកិច្ចការថ្មីដែលតម្រូវឱ្យមានការសិក្សាស្វែងយល់អំពីបទពិសោធន៍ដែលបានអនុវត្តទាំងនៅក្នុងប្រទេសក្នុងតំបន់ និងក្រៅតំបន់ ព្រមទាំងតម្រូវឱ្យមានការពិភាក្សា និងពិគ្រោះយោបល់យ៉ាងល្អិតល្អន់ក្នុងកម្រិតបច្ចេកទេសជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងជាមួយតំណាងរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

## ២.៤. ការវិភាគ និងដំណោះស្រាយ

ជាទូទៅ ការធ្វើអធិការកិច្ច គឺជាការត្រួតពិនិត្យវាយតម្លៃដែលមានលក្ខណៈឯករាជ្យ និងមិនលំអៀងទៅលើការអនុវត្តតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តិ ប្រព័ន្ធ នីតិវិធី និងស្តង់ដារដែលបានកំណត់។ ក្នុងក្របខណ្ឌនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គោលបំណងសំខាន់នៃការរៀបចំឱ្យមានប្រព័ន្ធធ្វើអធិការកិច្ច គឺមិនត្រឹមតែផ្តោតទៅលើការធានាថា រដ្ឋបាលថ្នាក់ក្រោមជាតិធ្វើការគ្រប់គ្រង ចាត់ចែង ប្រើប្រាស់ធនធានស្របតាមក្របខណ្ឌច្បាប់ ឬស្តង់ដារដែលបានកំណត់ប៉ុណ្ណោះឡើយ ក៏ប៉ុន្តែថែមទាំងផ្តោតទៅលើការកាត់បន្ថយនូវការធ្វើអន្តរាគមន៍ ឬការត្រួតពិនិត្យផ្នែករដ្ឋបាលទៅលើកិច្ចប្រតិបត្តិការប្រចាំថ្ងៃរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ស្វ័យភាព និងគំនិតផ្តួចផ្តើមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងបង្កើតនូវប្រព័ន្ធលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានស្របតាមក្របខណ្ឌច្បាប់ និងស្តង់ដារដែលបានកំណត់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋប្រកបដោយការទទួលខុសត្រូវ គណនេយ្យភាព និងប្រសិទ្ធភាព។

ក្នុងន័យនេះ ការយឺតយ៉ាវក្នុងការរៀបចំ និងអនុម័តក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់ការធ្វើអធិការកិច្ចទៅលើការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ មិនត្រឹមតែអាចធ្វើឱ្យ គ.ជ.អ.ប និងក្រសួង ស្ថាប័នពុំអាចមានលទ្ធភាពទទួលបានភស្តុតាងនានាអំពីស្ថានភាព និងប្រសិទ្ធភាពនៃការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមក្របខណ្ឌច្បាប់នោះឡើយ ថែមទាំងអាចពន្យារឱ្យមានការបន្តត្រួតពិនិត្យផ្នែករដ្ឋបាលទៅលើការអនុវត្តការងារប្រចាំថ្ងៃរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាឧបសគ្គក្នុងការលើកកម្ពស់ស្វ័យភាព ការទទួលខុសត្រូវ និងគំនិតផ្តួចផ្តើមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តតួនាទី និងមុខងារតាមអាណត្តិរបស់ខ្លួនផងដែរ។ ការយឺតយ៉ាវក្នុងការដាក់ឱ្យអនុវត្តនូវយន្តការអធិការកិច្ចនេះ ក៏អាចធ្វើឱ្យក្រសួង ស្ថាប័នមានភាពស្ទាក់ស្ទើរក្នុងការផ្ទេរមុខងារ និងធនធានឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

ដើម្បីធានាដោះស្រាយបញ្ហានេះ ក្រសួងមហាផ្ទៃត្រូវបន្តផ្តល់អាទិភាពដល់ការរៀបចំឱ្យមានការពិគ្រោះយោបល់លើសេចក្តីព្រាងក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់ការធ្វើអធិការកិច្ចលើការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រូវរៀបចំបញ្ចប់នូវក្របខណ្ឌយុទ្ធសាស្ត្រនេះ ដើម្បីធ្វើជាមូលដ្ឋានក្នុងការរៀបចំសេចក្តីណែនាំស្តីពីអធិការកិច្ចទៅលើការអនុវត្តតាមក្របខ័ណ្ឌគតិយុត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយអាចធ្វើការបណ្តុះបណ្តាលអំពីសៀវភៅណែនាំនេះ និងចាប់ផ្តើមអនុវត្តការធ្វើអធិការកិច្ចទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួននៅឆ្នាំ២០១៦។

# ៣. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស

## ៣.១. ចំណុចដៅជាអាទិភាពភាព

ការផ្តល់ស្វ័យភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស គឺជាកត្តាចាំបាច់សម្រាប់ធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិបំពេញមុខងារ ប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ក្នុងអំឡុងពេលនៃផអ៣ទី១ រដ្ឋបាលថ្នាក់ក្រោមជាតិបានទទួលនូវការធ្វើប្រតិភូកម្មអំណាចជាបណ្តើរៗ ក្នុងការគ្រប់គ្រង ចាត់ចែងមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ។ ផអ៣ទី២នេះនឹងបន្តជំរុញដល់ការរៀបចំ

បង្កើតនូវប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈជាអចិន្ត្រៃយ៍ សំដៅផ្តល់ស្វ័យភាពកាន់តែច្រើនឡើងបន្ថែមទៀតដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការគ្រប់គ្រង និងចាត់ចែងបុគ្គលិករបស់ខ្លួន។ ដើម្បីធានាដល់ការសម្រេចបាននូវគោលបំណងនេះ ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៥ របស់ គ.ជ.អ.ប បានកំណត់នូវចំណុចដៅជាអាទិភាពចំនួន៣ដែលត្រូវរៀបចំ និងអនុវត្តដោយក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ចំណុចដៅជាអាទិភាពទាំង៣នេះរួមមាន៖

- **ការរៀបចំលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ** ដោយផ្តោតជាសំខាន់ទៅលើការរៀបចំប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងអភិវឌ្ឍធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលធានាដល់ការផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង និងការចាត់ចែងមន្ត្រី បុគ្គលិកដែលបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

សូចនាករសំខាន់ៗសម្រាប់វាស់វែងស្ថានភាពនៃការសម្រេចបាននូវអាទិភាពនេះ គឺការរៀបចំ និងដាក់ចេញនូវលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ការរៀបចំលិខិតបទដ្ឋាននានាសម្រាប់ការអនុវត្តលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធ និងកិច្ចដំណើរការគ្រប់គ្រង ធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

- **ការរៀបចំវគ្គបណ្តុះបណ្តាលជាកាតព្វកិច្ចអំពីការបញ្ជ្រាបយេនឌ័រ និងការពង្រឹងភាពអង់អាចដល់ស្ត្រី** ដោយផ្តោតជាសំខាន់ទៅលើការបង្កើនសមត្ថភាព និងការយល់ដឹងរបស់ថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិអំពីបញ្ហាយេនឌ័រ និងការលើកកម្ពស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំ។ វគ្គបណ្តុះបណ្តាលទាំងនេះនឹងជួយឱ្យថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិពង្រឹងការអនុវត្តជាក់ស្តែងក្នុងការគ្រប់គ្រងការងារប្រចាំថ្ងៃរបស់ខ្លួន ប្រកបដោយការឆ្លើយតបទៅនឹងតម្រូវការរបស់ស្ត្រី និងសមធម៌សង្គម។

សូចនាករសំខាន់ៗសម្រាប់វាស់វែងស្ថានភាពនៃការសម្រេចបាននូវអាទិភាពនេះ គឺការរៀបចំកម្មវិធីបណ្តុះបណ្តាល ការរៀបចំឯកសារបណ្តុះបណ្តាល ការរៀបចំវគ្គបណ្តុះបណ្តាល និងការអនុវត្តសកម្មភាពជាក់ស្តែងរបស់ថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធទៅនឹងការជំរុញការឆ្លើយតប និងការពង្រឹងភាពអង់អាចដល់ស្ត្រី។

- **ការបង្កើតមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត** ផ្តោតលើការរៀបចំយន្តការថ្មីមួយសម្រាប់សម្របសម្រួល និងកៀរគរការគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកតាមតម្រូវការជាក់ស្តែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងផ្អែកតាមការតម្រូវពីថ្នាក់ជាតិ។

សូចនាករសំខាន់ៗសម្រាប់វាស់វែងស្ថានភាពនៃការសម្រេចបានចំណុចដៅជាអាទិភាពនេះ គឺការរៀបចំ និងដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំស្តីពីការបង្កើត និងការគ្រប់គ្រងមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត ការរៀបចំផែនការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ការ

រៀបចំបញ្ជីស្ថាប័ន និងអ្នកផ្តល់សេវាអភិវឌ្ឍសមត្ថភាពនៅតាមរាជធានី ខេត្តនីមួយៗ ការអនុវត្តផែនការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ និងការសិក្សាវាយតម្លៃលើគុណភាពនៃការអភិវឌ្ឍសមត្ថភាព ក្រោមការសម្របសម្រួលរបស់មណ្ឌលធនធានមនុស្សរាជធានី ខេត្ត។

### ៣.២. វឌ្ឍនភាព

ក្នុងឆ្នាំ២០១៥ ចំណុចដៅជាអាទិភាពនានាដែលបានកំណត់ខាងលើ ត្រូវបានអនុវត្ត និងសម្រេចបានលទ្ធផលតាមសូចនាករមួយចំនួនដែលបានកំណត់ ។ ស្ថានភាពនៃការអនុវត្ត និងការសម្រេចបានតាមសូចនាករនៃចំណុចដៅជាអាទិភាពទាំងនោះ រួមមានសង្ខេបដូចខាងក្រោម៖

**ការរៀបចំលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

ក្នុងឆ្នាំ២០១៥នេះ ក្រសួងមុខងារសាធារណៈ បានសហការជាមួយក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប បន្តរៀបចំឱ្យមានការពិនិត្យ ពិភាក្សាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានាទៅលើសេចក្តីព្រាងលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិក រដ្ឋបាលថ្នាក់ក្រោមជាតិដែលបានរៀបចំនៅក្នុងឆ្នាំ២០១៤។ ផ្អែកលើលទ្ធផលនៃការពិភាក្សាពិគ្រោះយោបល់លក្ខណៈបច្ចេកទេសច្រើនលើកច្រើនសារ ក្រសួងមុខងារសាធារណៈបានកែលំអសេចក្តីព្រាងលក្ខន្តិកៈនេះ ដើម្បីត្រៀមដាក់ជូនកិច្ចប្រជុំ គ.ជ.អ.ប ពិនិត្យ សម្រេច និងផ្តល់គោលការណ៍ណែនាំតម្រង់ទិសផ្នែកនយោបាយ។

**ការរៀបចំវគ្គបណ្តុះបណ្តាលជាកាតព្វកិច្ចអំពីការបញ្ជ្រាបយេនឌ័រ និងការពង្រឹងនាពអង់អាចដល់ស្ត្រី**

កិច្ចការសំខាន់ដែលពាក់ព័ន្ធការរៀបចំវគ្គបណ្តុះបណ្តាលជាកាតព្វកិច្ចដល់ថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិអំពីបញ្ហាយេនឌ័រ និងការលើកកម្ពស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំ នៅក្នុងឆ្នាំ២០១៥នេះ ក្រោមការសម្របសម្រួល និងការគាំទ្រពីក្រសួងកិច្ចការនារី និងលេខាធិការដ្ឋាន គ.ជ.អ.ប រដ្ឋបាលរាជធានី ខេត្តមួយចំនួនបានរៀបចំនូវកម្មវិធី និងឯកសារបណ្តុះបណ្តាល និងរដ្ឋបាលខេត្តមួយចំនួន រួមមានរដ្ឋបាលខេត្តកណ្តាល ខេត្តសៀមរាបបានរៀបចំវគ្គបណ្តុះបណ្តាលដល់សមាជិកក្រុមប្រឹក្សាខេត្ត សមាជិកក្រុមប្រឹក្សាក្រុង សមាជិកក្រុមប្រឹក្សាស្រុក គណៈអភិបាល នាយករដ្ឋបាល នាយករងរដ្ឋបាល ប្រធាន អនុប្រធានទីចាត់ការ ប្រធាន និងអនុប្រធានការិយាល័យនៃសាលាខេត្ត នាយករដ្ឋបាល នាយករងរដ្ឋបាល ប្រធាន និងអនុប្រធានការិយាល័យ និងអង្គភាពនានានៃសាលាក្រុង ស្រុក។ វគ្គបណ្តុះបណ្តាលទាំងនេះ មានគោលបំណងបង្កើនការយល់ដឹងដល់ថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិអំពីទស្សនយេនឌ័រ ក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងបញ្ហាយេនឌ័រ និងពង្រឹងការផ្តោតការយកចិត្តទុកដាក់លើបញ្ហាយេនឌ័រក្នុងការធ្វើការសម្រេចចិត្ត ក៏ដូចជាការអនុវត្តការងារជាក់ស្តែងនៅក្នុងមូលដ្ឋានរបស់ខ្លួន។

**ការបង្កើតមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សរាជធានី ខេត្ត**

ពាក់ព័ន្ធការរៀបចំបង្កើតមណ្ឌលធនធនមនុស្សនៅរាជធានី ខេត្ត ក្នុងឆ្នាំ២០១៥នេះ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប បានរៀបចំ និងដាក់ចេញនូវសេចក្តីណែនាំស្តីពីការរៀបចំយន្តការគាំទ្រការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលតម្រូវឱ្យមានការរៀបចំបង្កើតនូវមណ្ឌល

ធនធានមនុស្សនៅតាមរាជធានី ខេត្ត។ ផ្អែកតាមសេចក្តីណែនាំនេះ រដ្ឋបាលរាជធានី ខេត្តទាំងអស់បាន រៀបចំបង្កើតមណ្ឌលធនធានមនុស្សរួចរាល់។ មណ្ឌលធនធានមនុស្សរាជធានី ខេត្តទាំងនោះក៏បាន និង កំពុងចាប់ផ្តើមដំណើរការជាបណ្តើរៗតាមតួនាទីដែលបានកំណត់។

### ៣.៣. បញ្ហាប្រឈម

ទោះបីសកម្មភាពជាអាទិភាពទាំង៣ដែលបានកំណត់ខាងលើត្រូវបានអនុវត្តក៏ដោយ ក៏នៅមាន បញ្ហាប្រឈមមួយចំនួនដែលត្រូវផ្តោតការយកចិត្តទុកដាក់ដោះស្រាយនៅក្នុងឆ្នាំបន្ទាប់។ បញ្ហាប្រឈមជា ចម្បងដែលត្រូវបន្តផ្តោតការយកចិត្តទុកដាក់ គឺការជំរុញបន្ថែមទៀតដល់ការរៀបចំ និងដាក់ឱ្យអនុវត្តនូវ លក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។ ការរៀបចំ និងដាក់ឱ្យអនុវត្តនូវលក្ខន្តិកៈ ដោយឡែកនេះ មានការយឺតយ៉ាវយ៉ាងខ្លាំងបើប្រៀបធៀបទៅនឹងក្របខណ្ឌពេលវេលាដែលបានកំណត់។ មូលហេតុសំខាន់ដែលបណ្តាលឱ្យមានភាពយឺតយ៉ាវនេះ គឺដោយសារក្រុមការងារបច្ចេកទេសនៃក្រសួង មុខងារសាធារណៈ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវធ្វើការពិនិត្យ សិក្សា និងកែសម្រួល ឡើងវិញលើខ្លឹមសារនៃសេចក្តីព្រាងលក្ខន្តិកៈដោយឡែកដែលបានរៀបចំក្នុងឆ្នាំ២០១៤កន្លងមក ដើម្បី ធានាឱ្យស្របទៅនឹងខ្លឹមសារនៃគោលការណ៍រួមស្តីពីការរៀបចំមុខងារសាធារណៈ របស់រដ្ឋដែលបានដាក់ ចេញដោយរាជរដ្ឋាភិបាលនៅចុងឆ្នាំ២០១៤។ ក្នុងកិច្ចដំណើរការពិនិត្យឡើងវិញនេះក៏តម្រូវឱ្យមានការ សិក្សាស្វែងយល់ពីបទពិសោធន៍ដែលបានអនុវត្តនៅក្នុងប្រទេសក្នុងតំបន់ និងក្រៅតំបន់ និងតម្រូវឱ្យមាន ការពិភាក្សា ពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិជាច្រើនលើកច្រើនសារ បន្ថែមទៀត ដែលការងារទាំងនេះត្រូវការចំណាយពេលវេលាយ៉ាងច្រើន។

ផ្អែកតាមស្ថានភាពជាក់ស្តែង បើទោះបីចំនួនស្ត្រីត្រូវបានបង្កើនជាបន្តបន្ទាប់ក្នុងមុខតំណែងនានា ជាពិសេសមុខតំណែងជាថ្នាក់ដឹកនាំ និងអ្នកធ្វើសេចក្តីសម្រេចចិត្តនៃរដ្ឋបាលថ្នាក់ក្រោមជាតិក៏ដោយ ក៏បើ ពិនិត្យទៅលើស្ថានភាពទូទៅនៃការលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងកិច្ចដំណើរការកំណែទម្រង់ការ អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នៅតែមានបញ្ហាប្រឈមជាច្រើនដែលត្រូវបន្តជំរុញ ដោះស្រាយ។ ការបន្តពង្រឹងសមត្ថភាពរបស់ស្ត្រី ការជំរុញឱ្យមានការផ្តោតការយកចិត្តទុកដាក់ជាប្រចាំ របស់ថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការបង្កបរិកាស និងផ្តល់ឱកាសឱ្យបានទូលំទូលាយដល់ស្ត្រី ក្នុងការបំពេញការងារ និងចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តនានា និងជាពិសេសការបន្តបង្កើនចំនួនស្ត្រី ក្នុងមុខតំណែងជាអភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងជាមេឃុំ ចៅសង្កាត់ គឺជាកិច្ច ការដែលត្រូវផ្តោតការយកចិត្តទុកដាក់។

### ៣.៤. ការវិភាគ និងដំណោះស្រាយ

គោលបំណងសំខាន់នៃការរៀបចំលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ គឺ ដើម្បីបង្កើតប្រព័ន្ធគ្រប់គ្រងមន្ត្រី បុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលធានាដល់ការផ្តល់សិទ្ធិអំណាច ដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ការចាត់ចែង និងការអភិវឌ្ឍសមត្ថភាពមន្ត្រី បុគ្គលិកទាំងនោះ ប្រកបដោយប្រសិទ្ធភាព និងគណនេយ្យភាព ធានាដល់ការលើកទឹកចិត្តដល់មន្ត្រី បុគ្គលិកឱ្យទៅបំពេញ

ការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងធានាអព្យាក្រឹត្យភាពរបស់មន្ត្រី បុគ្គលិកក្នុងការបំពេញតួនាទីរបស់ខ្លួន ព្រមទាំងបង្កលក្ខណៈងាយស្រួលក្នុងការផ្ទេរមន្ត្រី បុគ្គលិកក្នុងកិច្ចដំណើរការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

ក្នុងន័យនេះ ការគិតគូរពិចារណាឱ្យបានល្អិតល្អន់ទៅលើខ្លឹមសារនៃលក្ខន្តិកៈដោយឡែក ដើម្បីធានាដល់ការឆ្លើយតបបានយ៉ាងពិតប្រាកដទៅនឹងគោលបំណងខាងលើ គឺជាកត្តាដ៏ចាំបាច់សម្រាប់ការលើកកម្ពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រងមន្ត្រី បុគ្គលិក លើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងលើកកម្ពស់ប្រសិទ្ធភាពការអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះដែរ ភាពយឺតយ៉ាវនៃការរៀបចំលក្ខន្តិកៈដោយឡែក ក៏ជាឧបសគ្គរាំងស្ទះដល់កិច្ចដំណើរការផ្ទេរមុខងារដែលជាសមាសធាតុស្នូលនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិផងដែរ។

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ ក្រសួងមុខងារសាធារណៈ ក្រសួងមហាផ្ទៃត្រូវបន្តសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងជាពិសេសជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការពិនិត្យពិគ្រោះយោបល់ និងពិចារណាឱ្យបានហ្មត់ចត់លើខ្លឹមសារនៃសេចក្តីព្រាងលក្ខន្តិកៈដោយឡែក ដើម្បីធានាដល់ការរៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងមន្ត្រី បុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលឆ្លើយតបបានទៅនឹងគោលបំណងខាងលើ និងត្រូវពន្លឿនកិច្ចដំណើរការនៃការរៀបចំបញ្ចប់នូវសេចក្តីព្រាងលក្ខន្តិកៈដោយឡែកនេះ ដើម្បីដាក់ជូនកិច្ចប្រជុំ គ.ជ.អ.ប ពិនិត្យ ពិភាក្សា និងផ្តល់គោលការណ៍ណែនាំតម្រង់ទិសផ្នែកនយោបាយ ព្រមទាំងត្រូវផ្តោតការយកចិត្តទុកដាក់ក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀតសម្រាប់ការអនុវត្តលក្ខន្តិកៈដោយឡែកនេះពីឆ្នាំ២០១៦តទៅ។

## ៤. ការផ្ទេរមុខងារនិងធនធានក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន

### ៤.១. សកម្មភាពជាអាទិភាពភាព

ការបន្តជំរុញកិច្ចដំណើរការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងការជំរុញឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានគំនិតផ្តួចផ្តើម និងគំនិតច្នៃប្រឌិតក្នុងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ គឺសមិទ្ធផលរំពឹងទុកដ៏ចាំបាច់មួយនៃផអ៣ទី២។ ដើម្បីធានាដល់ការសម្រេចបាននូវសមិទ្ធផលរំពឹងទុកនេះ ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥ របស់ គ.ជ.អ.ប បានកំណត់នូវចំណុចដៅជាអាទិភាពចំនួន៣ ដែលត្រូវអនុវត្តដោយក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ចំណុចដៅជាអាទិភាពទាំង៣នេះ រួមមាន៖

- ***ការធ្វើសេចក្តីសម្រេចចិត្តអំពីការផ្ទេរមុខងារ និងធនធានទៅរដ្ឋបាលថ្នាក់ក្រោមជាតិ*** ដោយផ្តោតទៅលើការសម្របសម្រួល និងការបន្តពិនិត្យពិភាក្សាទាំងក្នុងកម្រិតបច្ចេកទេស និងកម្រិតនយោបាយនៅក្នុងក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិទៅលើរបាយការណ៍ស្តីពីការរៀបចំបញ្ជីវិភាគមុខងារ និងការពិនិត្យមើលឡើងវិញនូវមុខងារ ដើម្បីឈានទៅធ្វើការសម្រេចចិត្តក្នុងការជ្រើសរើស និងការផ្ទេរនូវមុខងារជាក់លាក់ និងធនធានសមស្របក្នុងវិស័យអប់រំ សុខាភិបាល អភិវឌ្ឍន៍ជនបទ និងបរិស្ថានទៅឱ្យរដ្ឋ

បាលថ្នាក់ក្រោមជាតិ។

សូចនាករសំខាន់ៗសម្រាប់វាស់វែងស្ថានភាពនៃការសម្រេចបាននូវចំណុចដៅជាអាទិភាពនេះ គឺការសម្រេចចិត្តលើការផ្ទេរមុខងារពាក់ព័ន្ធនឹងវិស័យអប់រំ សុខាភិបាល បរិស្ថាន សង្គមកិច្ច និងអភិវឌ្ឍជនបទទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

• **ការផ្ទេរមុខងារពាក់ព័ន្ធនឹងការផ្តល់សេវាទីប្រជុំជនឱ្យទៅរដ្ឋបាលក្រុង** ដោយផ្តោតជាសំខាន់ទៅលើការផ្ទេរមុខងារផ្តល់សេវាទីប្រជុំជនពីរដ្ឋបាលខេត្តទៅឱ្យរដ្ឋបាលក្រុង សំដៅបង្វិតសេវាចាំបាច់ទាំងនោះឱ្យកាន់តែទៅកៀកជិតប្រជាពលរដ្ឋ និងលើកកម្ពស់គណនេយ្យភាពរបស់អ្នកផ្តល់សេវាចំពោះប្រជាពលរដ្ឋ និងចំពោះក្រុមប្រឹក្សាក្រុង។

សូចនាករសំខាន់ៗសម្រាប់វាស់វែងស្ថានភាពនៃការសម្រេចបាននូវចំណុចដៅអាទិភាពនេះ គឺការសិក្សា និងការវិភាគលើមុខងារផ្តល់សេវាទីប្រជុំជន ការកំណត់នូវមុខងារផ្តល់សេវាទីប្រជុំជនដែលត្រូវផ្ទេរពីរដ្ឋបាល ខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុក និងការរៀបចំសេចក្តីណែនាំ នីតិវិធី ផែនការ និងលិខិតបទដ្ឋានគតិយុត្តសម្រាប់ការផ្ទេរមុខងារផ្តល់សេវាទីប្រជុំជនចំនួនយ៉ាងតិច២ទៅឱ្យរដ្ឋបាលក្រុង ស្រុក។

• **ការរៀបចំ និងការផ្សព្វផ្សាយលិខិតបទដ្ឋានស្តីពីមុខងារជាជម្រើស និងសេវាសង្គម** ដោយផ្តោតជាសំខាន់ទៅលើការរៀបចំសេចក្តីណែនាំ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការជំរុញឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានគំនិតផ្តួចផ្តើមក្នុងការជ្រើសរើស និងការអនុវត្តនូវមុខងារជាជម្រើសនានាក្រោមក្របខណ្ឌនៃអាណត្តិទូទៅរបស់ខ្លួនផ្អែកតាមលទ្ធភាពធនធានដែលខ្លួនមាន ព្រមទាំងការរៀបចំនីតិវិធីសមស្របនានាសម្រាប់អនុវត្តមុខងារជាជម្រើសទាំងនោះក្នុងភាពជាដៃគូជាអង្គការសង្គមស៊ីវិល និងផ្នែកឯកជននានា ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។

សូចនាករសំខាន់ៗសម្រាប់វាស់វែងស្ថានភាពនៃការសម្រេចបាននូវអាទិភាពនេះ គឺការរៀបចំ និងដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋាននានាសម្រាប់អនុវត្តមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការរៀបចំកិច្ចប្រជុំជាមួយអង្គការសង្គមស៊ីវិល និងផ្នែកឯកជនដើម្បីពិភាក្សា និងឯកភាពគ្នាអំពីបែបផែននៃភាពជាដៃគូក្នុងកិច្ចសហការគ្នាអនុវត្តមុខងារជាជម្រើសក្រោមក្របខណ្ឌនៃអាណត្តិទូទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការបណ្តុះបណ្តាលដល់រដ្ឋបាលថ្នាក់ក្រោមជាតិអំពីនីតិវិធីនៃការជ្រើសរើស ការគ្រប់គ្រង និងការចាត់ចែងការអនុវត្តមុខងារជាជម្រើស និងការរៀបចំកិច្ចព្រមព្រៀងក្នុងភាពជាដៃគូរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយនឹងក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល និងផ្នែកឯកជនក្នុងការផ្តល់សេវាដែលជាការអនុវត្តមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានទឹកប្រាក់សរុបប្រមាណ៥០០.០០០ ដុល្លារ។

### ៤.២. វឌ្ឍនភាព

សកម្មភាពជាអាទិភាពខាងលើ គឺជាសកម្មភាពដែលត្រូវអនុវត្តបន្តពីឆ្នាំ២០១៤។ ផ្អែកលើមូលដ្ឋានដែលបានអនុវត្តនាពេលកន្លងមក ក្នុងឆ្នាំ២០១៥នេះយើងទទួលបាននូវលទ្ធផលជាផ្លែផ្កាគួជាទីមោទនៈមួយចំនួនបន្ថែមទៀតបើប្រៀបធៀបទៅនឹងសូចនាករនៃចំណុចដៅជាអាទិភាពដែលបានកំណត់។ ស្ថានភាព និងការអនុវត្ត និងការសម្រេចបានតាមសូចនាករទាំងនោះ រួមមានសង្ខេបដូចខាងក្រោម៖

**ការធ្វើសេចក្តីសម្រេចចិត្តអំពីការផ្ទេរមុខងារ និងធនធានទៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

ពាក់ព័ន្ធនឹងការធ្វើសេចក្តីសម្រេចចិត្តក្នុងការកំណត់នូវមុខងារជាក់លាក់សម្រាប់ផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងឆ្នាំ២០១៥នេះ លេខាធិការដ្ឋាន គ.ជ.អ.ប បានធ្វើការពិនិត្យ ពិភាក្សាជាមួយក្រសួងចំនួន៥ រួមមាន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងអភិវឌ្ឍជនបទ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងនីតិសម្បទា និងក្រសួងបរិស្ថានទៅលើបញ្ជីមុខងារដែលក្រសួងបានស្នើផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ។ ជាលទ្ធផល រាជរដ្ឋាភិបាលបានសម្រេចចិត្តរៀបចំ និងដាក់ចេញនូវអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម និងសំណល់រឹងទីប្រជុំជន ក្នុងគោលបំណងផ្ទេរជាអចិន្ត្រៃយ៍នូវមុខងារនេះពីរដ្ឋបាលខេត្តទៅឱ្យរដ្ឋបាល ក្រុង ស្រុក។ ទន្ទឹមគ្នានេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងនីតិសប្បទាក៏បានសម្រេចចិត្តដាក់ចេញនូវប្រកាសស្តីការធ្វើប្រតិភូកម្មមុខងារចំនួន៣ពាក់ព័ន្ធនឹងការគ្រប់គ្រង តាមដាន និងត្រួតពិនិត្យមណ្ឌលថែទាំកុមារទៅឱ្យរដ្ឋបាលខេត្តបាត់ដំបង និងរដ្ឋបាល ក្រុង ស្រុក និងឃុំ សង្កាត់ក្នុងខេត្តបាត់ដំបង។ លើសពីនេះ ក្រសួងសុខាភិបាល និងក្រសួងអភិវឌ្ឍជនបទក៏បានសម្រេចចិត្តផ្ទេរសាកល្បងនូវមុខងារចំនួន៣ គឺមុខងារគ្រប់គ្រង និងថែទាំមណ្ឌលសុខភាព មុខងារផ្តល់សេវាអនាម័យ ជនបទ និងមុខងារជួសជុល និងថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតទៅឱ្យរដ្ឋបាលស្រុកគោលដៅមួយចំនួនផងដែរ។ ផ្អែកលើបទពិសោធន៍នៃការផ្ទេរមុខងារគ្រប់គ្រង និងថែទាំមណ្ឌលសុខភាព ក្រសួងសុខាភិបាលបានលើកសំណើសម្រាប់ការផ្ទេរមុខងារសំណុំសកម្មភាពអប្បបរមានៃសេវាសុខាភិ បាលនៃស្រុកប្រតិបត្តិសុខាភិបាលមួយចំនួនទៅឱ្យរដ្ឋបាលក្រុង ស្រុកគោលដៅមួយចំនួនបន្ថែមទៀតនៅក្នុងឆ្នាំ២០១៦ខាងមុខ។ ក្នុងឆ្នាំ២០១៥នេះ បើទោះបីពុំទានមានមុខងារ សំខាន់ៗក្នុងវិស័យអប់រំ ត្រូវបានផ្ទេរជាអចិន្ត្រៃយ៍ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាក៏ដោយ ក៏ផ្អែកតាមការសម្របសម្រួល និងពិគ្រោះយោបល់ជាបន្តបន្ទាប់ទាំងក្នុងកម្រិតបច្ចេកទេស និងកម្រិតអ្នកនយោបាយ ក្រសួងអប់រំ យុវជន និងកីឡាបានឈានទៅធ្វើការសម្រេចចិត្តក្នុងការផ្ទេរមុខងារគ្រប់គ្រងការអប់រំកម្រិតបឋមសិក្សា ការអប់រំកុមារតូច និងការអប់រំក្រៅប្រព័ន្ធឱ្យទៅរដ្ឋបាល ក្រុង ស្រុកតាមដំណាក់កាលៗ។ ការផ្ទេរមុខងារទាំងនេះនឹងចាប់ផ្តើមនៅឆ្នាំ២០១៦។

ក្រៅពីនេះ ក្នុងឆ្នាំ២០១៥នេះ ក្រសួងចំនួន៨ រួមមាន ក្រសួងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងទេសចរណ៍ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងរ៉ែ និងថាមពល ក្រសួងសាធារណការ ក្រសួងធនធានទឹក និងឧតុនិយមបានចាប់ផ្តើមកិច្ចដំណើរការរៀបចំបញ្ជីវិភាគមុខងារទៅតាមជំហាន និងនីតិវិធីដែលបានកំណត់។

**ការផ្ទេរមុខងារពាក់ព័ន្ធនឹងការផ្តល់សេវាទីប្រជុំជនឱ្យទៅរដ្ឋបាលក្រុង**

ពាក់ព័ន្ធនឹងការផ្ទេរមុខងារផ្តល់សេវាទីប្រជុំជន លេខាធិការដ្ឋាន គ.ជ.អ.ប បានចាប់ផ្តើមចុះធ្វើការសិក្សាស្រាវជ្រាវ ប្រមូលព័ត៌មានពាក់ព័ន្ធនឹងប្រភេទសេវាទីប្រជុំជន និងស្ថានភាពនៃការគ្រប់គ្រងការផ្តល់សេវាទីប្រជុំជនទាំងនោះ ដោយបានធ្វើការពិគ្រោះយោបល់ជាបឋមជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធមួយចំនួន ក្នុងការកំណត់នូវមុខងារផ្តល់សេវាទីប្រជុំជនដែលមានលក្ខណៈសមស្របសម្រាប់ផ្ទេរទៅឱ្យរដ្ឋបាល ក្រុង ស្រុកនៅក្នុងឆ្នាំ២០១៦ខាងមុខនេះ។

**ការរៀបចំ និងការផ្សព្វផ្សាយលិខិតបទដ្ឋានស្តីពីមុខងារជាជម្រើស និងសេវាសង្គម**

ចំពោះសកម្មភាពជាអាទិភាពពាក់ព័ន្ធនឹងការជំរុញលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ ក្រោមជាតិក្នុងការផ្តួចផ្តើមគំនិតជ្រើសរើស និងអនុវត្តមុខងារជាជម្រើសក្នុងក្របខណ្ឌនៃអាណត្តិទូទៅរបស់ខ្លួន ក្នុងឆ្នាំ ២០១៥នេះ លេខាធិការដ្ឋាន គ.ជ.អ.ប បានរៀបចំនូវឯកសារបច្ចេកទេសស្តីពីនីតិវិធីនៃការជ្រើសរើស និងអនុវត្តនូវមុខងារជាជម្រើសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ឯកសារនេះគ្រោងនឹងដាក់ពិគ្រោះយោបល់ និងដាក់ឱ្យប្រើប្រាស់នៅដើមឆ្នាំ២០១៦ខាងមុខនេះ។

## ៤.៣. បញ្ហាប្រឈម

ទោះបីជាការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិគឺជាសមិទ្ធផលរំពឹងទុកដ៏មានសារសំខាន់មួយនៃផអ៣ទី២ និងជាសកម្មភាពដែលត្រូវបានផ្តល់អាទិភាពខ្ពស់ក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៥ របស់ គ.ជ.អ.ប ក៏ដោយ ក៏ការអនុវត្តសកម្មភាពជាអាទិភាពនេះ នៅមានភាពយឺតយ៉ាវ បើប្រៀបធៀបទៅនឹងសូចនាករដែលបានកំណត់។ មូលហេតុចម្បងនៃការអូសបន្លាយពេលវេលាក្នុងកិច្ចដំណើរការផ្ទេរមុខងារនេះ គឺដោយសារសេចក្តីណែនាំរបស់ គ.ជ.អ.ប ដែលបានដាក់ចេញនាពេលកន្លងមកពាក់ព័ន្ធនឹងកិច្ចដំណើរការផ្ទេរមុខងារ បានតម្រូវឱ្យក្រសួង ស្ថាប័នរៀបចំនូវបញ្ជីវិភាគមុខងារ និងពិនិត្យមើលឡើងវិញនូវមុខងារទាំងនោះ មានលក្ខណៈបច្ចេកទេសលម្អិតខ្លាំងពេក និងត្រូវអនុវត្តតាមលំដាប់លំដោយជាច្រើនជំហាន ហើយតម្រូវឱ្យមានការពិភាក្សាពិគ្រោះយោបល់យ៉ាងច្រើនជាមួយអង្គភាពក្រោមឱវាទ ព្រមទាំងលើកទឹកចិត្តឱ្យក្រសួង ស្ថាប័នធ្វើការជ្រើសរើសនូវមុខងារសម្រាប់ផ្ទេរទៅឱ្យរដ្ឋបាល ថ្នាក់ក្រោមជាតិក្នុងលក្ខណៈជាការស្ម័គ្រចិត្ត។

កិច្ចដំណើរការនេះ ក្រៅពីត្រូវការចំណាយពេលវេលាយូរ និងថវិកាច្រើន ក៏បានធ្វើឱ្យក្រសួង ស្ថាប័ននីមួយៗរៀបចំនូវបញ្ជីមុខងារដោយដាក់បញ្ចូលទាំងមុខងាររងតូចៗជាច្រើន និងស្នើឡើងនូវមុខងាររងមួយចំនួនតូចប៉ុណ្ណោះសម្រាប់ផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងពុំបានកំណត់នូវធនធានច្បាស់លាស់សម្រាប់ស្នើផ្ទេរភ្ជាប់ទៅជាមួយនឹងមុខងាររងទាំងនោះឡើយ។

លើសពីនេះ ជាគោលការណ៍ កិច្ចដំណើរការផ្ទេរមុខងារត្រូវផ្សារភ្ជាប់ជាមួយនឹងកិច្ចដំណើរការផ្ទេរធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស។ នាពេលបច្ចុប្បន្ននេះ ការរៀបចំនូវយន្តការផ្ទេរធនធានហិរញ្ញវត្ថុ (យន្តការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌ ឬការបង្កើតនូវប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ) និងយន្តការផ្ទេរធនធានមនុស្ស (លក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋាននានាសម្រាប់ការផ្ទេរមន្ត្រី បុគ្គលិក) ក៏មានការយឺតយ៉ាវផងដែរ។

## ៤.៤. ការវិភាគ និងដំណោះស្រាយ

ការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាគោលបំណងដ៏ចម្បងនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីបង្វិតសេវាឱ្យទៅកៀកជិតប្រជាពលរដ្ឋ និងលើកកម្ពស់ការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជា

ពលរដ្ឋប្រកបដោយការចូលរួម តម្លាភាព និងគណនេយ្យភាព។ ភាពយឺតយ៉ាវនៃការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានអូសបន្លាយជាច្រើនឆ្នាំកន្លងមកនេះ បានធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាលថ្នាក់ក្រុង ស្រុកពុំមានសិទ្ធិអំណាច និងការទទួលខុសត្រូវច្បាស់លាស់ព្រមទាំងពុំមានធនធានជាក់លាក់សម្រាប់គ្រប់គ្រង និងចាត់ចែងការផ្តល់សេវាសាធារណៈ និងកិច្ចអភិវឌ្ឍមូលដ្ឋានដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋក្នុងលក្ខណៈជាដុំកំភួនឡើយ។ ការបន្តអូសបន្លាយពេលវេលានៃការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនឹងធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមិនត្រឹមតែគ្មានលទ្ធភាព និងស្វ័យភាពក្នុងការអនុវត្តតួនាទីតាមអាណត្តិរបស់ខ្លួនឡើយថែមទាំងធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិបាត់បង់នូវការជឿជាក់ បាត់បង់នូវភាពជាម្ចាស់ និងការចូលរួមចំណែកក្នុងកិច្ចដំណើរការកំណែទម្រង់ផងដែរ។ លើសពីនេះ ភាពយឺតយ៉ាវនៃការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនឹងធ្វើឱ្យរាំងស្ទះដល់ឆន្ទៈនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យក្លាយទៅជាស្ថាប័នប្រជាធិបតេយ្យ ជាស្ថាប័នតំណាងប្រជាពលរដ្ឋ មានស្វ័យភាពក្នុងការផ្តួចផ្តើមគំនិត ការគ្រប់គ្រង ការចាត់ចែងការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋានដើម្បីឆ្លើយតបទៅនឹងស្ថានភាពនៃតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវ។

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវបន្តខិតខំសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ជាពិសេសក្រសួងអប់រំ ក្រសួងសុខាភិបាល ក្រសួងអភិវឌ្ឍជនបទក្រសួងសង្គមកិច្ច និងក្រសួងបរិស្ថាន ដើម្បីជំរុញការរៀបចំលិខិតបទដ្ឋានពាក់ព័ន្ធនានា ដើម្បីឈានទៅធ្វើការផ្ទេរមុខងារសមស្រប និងធនធានជាក់លាក់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងឆ្នាំ២០១៦ខាងមុខនេះ។ ទន្ទឹមគ្នានេះ រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ត្រូវបន្តពង្រឹងសមត្ថភាពស្ថាប័នរបស់ខ្លួន ដើម្បីធានាដល់ការទទួល ការគ្រប់គ្រង ការចាត់ចែងមុខងារដែលនឹងត្រូវផ្ទេរឱ្យប្រកបដោយប្រសិទ្ធភាព។

ជាមួយគ្នានេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ ក៏ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរួសរាន់រៀបចំបញ្ចប់នូវយន្តការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌ និងយន្តការផ្ទេរធនធានមនុស្សទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ធានាដល់ប្រសិទ្ធភាពនៃការអនុវត្តផ្ទេរមុខងារដែលនឹងត្រូវផ្ទេរទៅឱ្យ។

ក្រៅពីនេះ លេខាធិការដ្ឋាន គ.ជ.អ.ប ដោយផ្អែកលើបទពិសោធន៍ដែលបានអនុវត្តនាពេលកន្លងមក ត្រូវធ្វើការសិក្សា និងកែសម្រួលសេចក្តីណែនាំពាក់ព័ន្ធនឹងកិច្ចដំណើរការផ្ទេរមុខងារ ដើម្បីកាត់បន្ថយនូវជំហាន ឬសកម្មភាពដែលពុំចាំបាច់ និងមានលក្ខណៈស្មុគស្មាញនានា ឱ្យមានលក្ខណៈសាមញ្ញ ក៏ប៉ុន្តែអាចកំណត់បាននូវមុខងារ និងធនធានសមស្របសម្រាប់ផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយប្រើពេលវេលាខ្លីជាងមុន។

## ៥. វិមជ្ឈការហិរញ្ញវត្ថុ

### ៥.១. សកម្មភាពជាអាទិភាពភាព

គោលបំណងសំខាន់នៃវិមជ្ឈការហិរញ្ញវត្ថុ គឺដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានប្រភព

ធនធានហិរញ្ញវត្ថុ មានប្រព័ន្ធ មាននីតិវិធី និងមានសមត្ថភាពសមស្របសម្រាប់គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុទាំងនោះក្នុងការអនុវត្តតួនាទីភារកិច្ច និងមុខងារតាមអាណត្តិរបស់ខ្លួនយ៉ាងមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។ សមិទ្ធផលរំពឹងទុកពាក់ព័ន្ធនឹងវិមជ្ឈការហិរញ្ញវត្ថុក្នុងក្របខណ្ឌនៃផអ៣ទី២ បានផ្ដោតជាសំខាន់ទៅលើការបន្តពង្រឹងការអនុវត្តមូលនិធិក្រុង ស្រុក និងការរៀបចំយន្តការនានាសម្រាប់ការផ្ទេរធនធានមានភ្ជាប់ល័ក្ខខ័ណ្ឌ យន្តការផ្តល់មូលនិធិវិនិយោគដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ការបង្កើតប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការកែលំអប្រព័ន្ធផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ដើម្បីធានាដល់ការសម្រេចបាននូវសមិទ្ធផលរំពឹងទុកនេះ ផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥របស់ គ.ជ.អ.ប បានផ្តោតជាសំខាន់ទៅលើចំណុចដៅជាអាទិភាពចំនួន៥ រួមមាន៖

• **ការកែលំអប្រព័ន្ធ និងនីតិវិធីអនុវត្តមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់** ដោយផ្តោតទៅលើការសិក្សាការពិនិត្យឡើងវិញ និងការកំណត់នូវបញ្ហាប្រឈមជាគន្លឹះនានានៃការអនុវត្តមូលនិធិក្រុង ស្រុក ដើម្បីស្វែងរកដំណោះស្រាយសមស្របដែលធានាដល់ការកែលំអប្រព័ន្ធគ្រប់គ្រងមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ឱ្យមានលក្ខណៈកាន់តែល្អប្រសើរឡើង។

សូចនាករសំខាន់ៗសម្រាប់វាស់វែងស្ថានភាពនៃការសម្រេចបាននូវអាទិភាពនេះ គឺការសិក្សាអំពីបញ្ហាប្រឈមនានានៃការអនុវត្តមូលនិធិក្រុង ស្រុក និងមូលនិធិ ឃុំ សង្កាត់ដោយផ្តោតទៅលើនីតិវិធីនៃការប្រើប្រាស់មូលនិធិទាំងនេះសម្រាប់ការផ្តល់សេវាសង្គម ការកែសម្រួលសេចក្តីណែនាំស្តីប្រព័ន្ធគ្រប់គ្រងមូលនិធិក្រុង ស្រុក និងការរៀបចំវគ្គបណ្តុះបណ្តាលអំពីប្រព័ន្ធ និងនីតិវិធីដែលបានកែសម្រួលទាំងនេះ។

• **ការកៀរគរធនធានពីដៃគូអភិវឌ្ឍន៍នានាដើម្បីគាំទ្រមូលនិធិក្រុង ស្រុកផ្នែកអភិវឌ្ឍន៍** ដោយផ្តោតទៅលើការពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានាក្នុងន័យកៀរគរធនធានសម្រាប់បន្ថែមទៅលើមូលនិធិក្រុង ស្រុក ដើម្បីធានាឱ្យបានថា មូលនិធិក្រុង ស្រុកផ្នែកអភិវឌ្ឍន៍ពីឆ្នាំ២០១៦តទៅនឹងមានចំនួនប្រមាណ0,៥0% ធៀបទៅនឹងចំណូលចរន្តសរុបនៃថវិការដ្ឋ។

សូចនាករសំខាន់ៗសម្រាប់វាស់វែងស្ថានភាពនៃការសម្រេចបាននូវអាទិភាពនេះ គឺការប្រឹក្សាយោបល់ជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីកៀរគរធនធានសម្រាប់បន្ថែមទៅលើមូលនិធិក្រុង ស្រុកផ្នែកអភិវឌ្ឍន៍ពីឆ្នាំ ២០១៦-២០១៨ ឱ្យបាន0,៥%នៃចំណូលចរន្តសរុបនៃថវិការដ្ឋ។

• **យន្តការផ្ទេរធនធានមានភ្ជាប់ល័ក្ខខ័ណ្ឌ** ផ្តោតទៅលើការរៀបចំ និងដាក់ឱ្យអនុវត្តនូវយន្តការផ្ទេរធនធានមានភ្ជាប់ល័ក្ខខ័ណ្ឌដើម្បីធានាដល់ការផ្ទេរមូលនិធិឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ប្រើប្រាស់ក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តនូវមុខងារដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទាំងនោះ។

សូចនាករសំខាន់ៗសម្រាប់វាស់វែងស្ថានភាពនៃការសម្រេចបាននូវអាទិភាពនេះ គឺការរៀបចំលិខិតបទដ្ឋានស្តីពីយន្តការផ្ទេរធនធានមានភ្ជាប់ល័ក្ខខ័ណ្ឌ ការផ្ទេរធនធានមានភ្ជាប់ល័ក្ខខ័ណ្ឌភ្ជាប់ជាមួយនឹងការផ្ទេរមុខងារ និងការពិនិត្យ និងកែសម្រួលរូបមន្តនៃការវិភាជថវិការាជធានី ខេត្ត ដើម្បីធានាប្រសិទ្ធភាពនៃការវិភាជថវិកា។

• **ការរៀបចំបង្កើតលេខាធិការដ្ឋានទទួលបន្ទុកយន្តការផ្តល់មូលនិធិវិនិយោគដល់រដ្ឋបាលថ្នាក់ក្រោមជាតិ** ផ្តោតជាសំខាន់ទៅលើការរៀបចំក្របខ័ណ្ឌគតិយុត្ត និងរចនាសម្ព័ន្ធសម្រាប់គ្រប់គ្រងយន្តការផ្តល់មូលនិធិវិនិយោគដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងគោលបំណងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចនៅថ្នាក់ក្រោមជាតិដោយរៀបចំ និងដាក់ឱ្យអនុវត្តនូវយន្តការផ្តល់មូលនិធិបន្ថែមដែលមានលក្ខណៈជាយុទ្ធសាស្ត្រសម្រាប់គាំទ្រគម្រោងវិនិយោគសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងផ្តល់ការលើកទឹកចិត្តដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការលើកកម្ពស់ការបំពេញភារកិច្ច និងការគ្រប់គ្រងការវិនិយោគសាធារណៈឱ្យកាន់តែមានលក្ខណៈល្អប្រសើរ។

សូចនាករសំខាន់ៗសម្រាប់វាស់វែងស្ថានភាពនៃការសម្រេចបាននូវអាទិភាពនេះ គឺការរៀបចំលេខាធិការដ្ឋានទទួលបន្ទុកប្រតិបត្តិការយន្តការផ្តល់មូលនិធិវិនិយោគដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងសៀវភៅណែនាំនានាសម្រាប់អនុវត្តយន្តការផ្តល់មូលនិធិវិនិយោគដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការរៀបចំសំណើគម្រោងសម្រាប់ការផ្តល់ហិរញ្ញប្បទានគាំទ្រដល់យន្តការនេះពីធនាគារអភិវឌ្ឍន៍អាស៊ី។

• **ការកែសម្រួលសេចក្តីណែនាំបច្ចេកទេសស្តីពីការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** ផ្តោតទៅលើការសិក្សា និងការកែសម្រួលប្រព័ន្ធកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យស្របតាមគោលនយោបាយស្តីពីប្រព័ន្ធផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលនាចុងឆ្នាំ២០១៤ កន្លងមក។

សូចនាករសំខាន់ៗសម្រាប់វាស់វែងស្ថានភាពនៃការសម្រេចបាននូវអាទិភាពនេះ គឺការសិក្សា ការកែសម្រួល និងការដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំបច្ចេកទេសស្តីពីការកសាងផែនការ និងសេចក្តីណែនាំពាក់ព័ន្ធនឹងការរៀបចំ ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីសេចក្តីណែនាំដែលបានកែសម្រួល។

### ៥.២. វឌ្ឍនភាព

ក្នុងឆ្នាំ២០១៥នេះ ចំណុចដៅជាអាទិភាពសំខាន់ៗដូចបានរៀបរាប់ខាងលើត្រូវបានអនុវត្ត និងទទួលបានលទ្ធផលដូចខាងក្រោម៖

***ការកែលំអប្រព័ន្ធ និងនីតិវិធីអនុវត្តមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់***

តាមរយៈប្រព័ន្ធរបាយការណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប បានទទួលនូវព័ត៌មានមួយចំនួនពាក់ព័ន្ធនឹងស្ថានភាព និងបញ្ហាប្រឈមនានាក្នុងការផ្ទេរ និងការប្រើប្រាស់មូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ ជាពិសេស បញ្ហាប្រឈមពាក់ព័ន្ធនឹងភាពយឺតយ៉ាវនៃការផ្ទេរមូលនិធិ ការលំបាកក្នុងការប្រើប្រាស់មូលនិធិនេះសម្រាប់គាំទ្រសកម្មភាពសេវាសង្គម និងភាពមិនប្រក្រតីនៃកិច្ចលទ្ធកម្មគម្រោងមូលនិធិឃុំ សង្កាត់ និងមូលនិធិក្រុង ស្រុកមួយចំនួនជាដើម។ ផ្អែកលើព័ត៌មានដែលទទួលបានទាំងនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប បានពិភាក្សា និងបានចាត់វិធានការនានាសម្រាប់ដោះស្រាយបញ្ហា

ប្រឈមទាំងនោះបានមួយចំនួន។ ទន្ទឹមគ្នានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏បានរៀបចំក្រុមការងារអន្តរក្រសួងមួយដែលមានសមាសភាពមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីចុះទៅធ្វើការសិក្សាស្រាវជ្រាវនៅតាមមូលដ្ឋានជាក់ស្តែង ប្រមូលនូវព័ត៌មាន និងកំណត់នូវបញ្ហាប្រឈមជាគន្លឹះដែលបានជួបប្រទះ ដើម្បីឈានទៅធ្វើការកែលំអប្រព័ន្ធ និងនីតិវិធីនៃការផ្ទេរ និងការប្រើប្រាស់មូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់ឱ្យកាន់តែល្អប្រសើរដែលធានាដល់ការដោះស្រាយបញ្ហាប្រឈមបានទាន់ពេលវេលា និងមានលក្ខណៈជាប្រព័ន្ធ។

**ការកៀរគរធនធានពីដៃគូអភិវឌ្ឍន៍នានាដើម្បីគាំទ្រមូលនិធិក្រុង ស្រុកផ្នែកអភិវឌ្ឍន៍**

ក្នុងឆ្នាំ២០១៥នេះ លេខាធិការដ្ឋាន គ.ជ.អ.ប បានជួបពិភាក្សាជាបឋមជាមួយដៃគូអភិវឌ្ឍន៍ ជាពិសេសជាមួយតំណាងសហភាពអឺរ៉ុបអំពីលទ្ធភាពនៃផ្តល់ហិរញ្ញប្បទានរបស់សហភាពអឺរ៉ុបក្នុងការបន្តគាំទ្រដល់កម្មវិធីកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រួមទាំងការចូលរួមចំណែកគាំទ្រដល់មូលនិធិក្រុង ស្រុកផ្នែកអភិវឌ្ឍន៍ចាប់ពីឆ្នាំ២០១៦តទៅ។ ទោះជាយ៉ាងនេះក្តី ដោយសារសហភាពអឺរ៉ុបត្រូវការពេលវេលាសមស្របមួយសម្រាប់ធ្វើការសិក្សាវាយតម្លៃអំពីស្ថានភាពនៃការអនុវត្តគម្រោងចាស់ដែលនឹងត្រូវបញ្ចប់នៅចុងឆ្នាំ២០១៦នេះ និងការសិក្សាអំពីលទ្ធភាពក្នុងរៀបចំគម្រោងថ្មីមួយផ្សេងទៀតសម្រាប់បន្តការគាំទ្រ ដែលកិច្ចដំណើរការរៀបចំគម្រោងថ្មីនេះអាចនឹងប្រើពេលវេលាក្នុងឆ្នាំ២០១៦។ អាស្រ័យហេតុនេះ ការបន្តគាំទ្រហិរញ្ញប្បទានរបស់សហភាពអឺរ៉ុបតាមរយៈគម្រោងថ្មីនេះពុំអាចចាប់ផ្តើមនៅឆ្នាំ២០១៦បានឡើយ។ ក្នុងន័យនេះ ការកៀរគរធនធានពីដៃគូអភិវឌ្ឍន៍ ជាពិសេសពីសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់មូលនិធិក្រុង ស្រុកផ្នែកអភិវឌ្ឍន៍នៅក្នុងឆ្នាំ២០១៦ខាងមុខនេះពុំបានសម្រេចតាមសូចនាករដែលបានគ្រោងទុកឡើយ។

**យន្តការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌ**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលេខាធិការដ្ឋាន គ.ជ.អ.ប បានសហការជាមួយក្រសួងអភិវឌ្ឍន៍ជនបទក្នុងការអនុវត្តសាកល្បងនូវការផ្ទេរធនធានមានភ្ជាប់ល័ក្ខខ័ណ្ឌទៅឱ្យរដ្ឋបាលស្រុកគោលដៅមួយចំនួនសម្រាប់ការអនុវត្តមុខងារជួសជុលថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ និងទៅឱ្យរដ្ឋបាលស្រុកគោលដៅមួយចំនួនផ្សេងទៀតសម្រាប់អនុវត្តនូវមុខងារផ្តល់សេវាអនាម័យជនបទ។ ជាមួយគ្នានេះ ការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌនេះក៏កំពុងផ្ទេរទៅឱ្យរដ្ឋបាលក្រុងទាំង២៦សម្រាប់ការអនុវត្តមុខងារពាក់ព័ន្ធនឹងការផ្តល់សេវា អនាម័យបរិស្ថានផងដែរ។ ការអនុវត្តសាកល្បងនៃការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌទាំងនេះនឹងត្រូវធ្វើការសិក្សាវាយតម្លៃ ដើម្បីចងក្រងមេរៀន និងបទពិសោធន៍សម្រាប់ការរៀបចំឯកសារគតិយុត្តិស្តីពីយន្តការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌនៅឆ្នាំ២០១៦ខាងមុខនេះ។

**ការរៀបចំបង្កើតលេខាធិការដ្ឋានទទួលបន្ទុកយន្តការផ្តល់មូលនិធិវិនិយោគដល់រដ្ឋបាលថ្នាក់ក្រោមជាតិ**

ចំពោះសកម្មភាពជាអាទិភាពពាក់ព័ន្ធនឹងការរៀបចំបង្កើតលេខាធិការដ្ឋានទទួលបន្ទុកយន្តការផ្តល់មូលនិធិវិនិយោគដល់រដ្ឋបាលថ្នាក់ក្រោមជាតិ បើទោះបីជាក្នុងឆ្នាំ២០១៥នេះ នៅពុំទាន់ត្រូវបង្កើត និងដាក់ឱ្យដំណើរការនូវលេខាធិការដ្ឋាននេះក៏ដោយ ក៏លទ្ធផលជាគន្លឹះពាក់ព័ន្ធនឹងចំណុចដៅជាអាទិភាពនេះ គឺ

ការរៀបចំនូវសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជារួម ក្រោមការដឹកនាំ និងសម្របសម្រួលរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សេចក្តីព្រាងអនុក្រឹត្យនេះត្រូវបានរៀបចំបញ្ចប់ដោយមានការពិភាក្សា ពិគ្រោះយោបល់ជាច្រើនលើកច្រើនសារក្នុងកម្រិតបច្ចេកទេសជាមួយតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធនានា។ អនុក្រឹត្យនេះ ជាក្របខណ្ឌគតិយុត្តដ៏មានសារៈសំខាន់សម្រាប់ការរៀបចំបង្កើតលេខាធិការដ្ឋានទទួលបន្ទុកប្រតិបត្តិការមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ការកែសម្រួលសេចក្តីណែនាំបច្ចេកទេសស្តីពីការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

ក្នុងឆ្នាំ២០១៥នេះ ក្រសួងផែនការបានសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងការរៀបចំបង្កើតក្រុមការងារមួយ ព្រមទាំងបានរៀបចំនូវផែនការការងារសម្រាប់ការចុះទៅសិក្សាវាយតម្លៃអំពីស្ថានភាពជាក់ស្តែងនៅតាមមូលដ្ឋានមួយចំនួន។ ផ្អែកលើលទ្ធផលនៃការសិក្សាវាយតម្លៃនេះ ក្រសួងផែនការបានសម្របសម្រួលជាមួយក្រសួង ស្ថាប័ន អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំកែសម្រួលសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំកម្មវិធីវិនិយោគរបស់រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក និងរដ្ឋបាលឃុំឱ្យកាន់តែមានលក្ខណៈល្អប្រសើរ ឆ្លើយតបយ៉ាងសមស្របទៅនឹងចរិកលក្ខណៈនៃប្រភេទរដ្ឋបាលទាំងនោះ។

### ៥.៣. បញ្ហាប្រឈម

ទោះបីសកម្មភាពជាអាទិភាពដូចបានរៀបរាប់ខាងលើត្រូវបានចាប់ផ្តើមអនុវត្តស្ទើរតែទាំងអស់ក្តី ក៏នៅមានបញ្ហាប្រឈមសំខាន់ៗមួយចំនួនដែលត្រូវផ្តោតការយកចិត្តទុកដាក់បន្តដោះស្រាយ និងអនុវត្តនៅក្នុងឆ្នាំបន្ទាប់។ បញ្ហាប្រឈមសំខាន់ៗទាំងនោះរួមមាន៖

រដ្ឋបាលឃុំ សង្កាត់នៅតែជួបការលំបាក និងមានភាពស្មុគស្មាញក្នុងការប្រើប្រាស់មូលនិធិឃុំ សង្កាត់សម្រាប់ចំណាយលើសកម្មភាព ឬគម្រោងផ្តល់សេវាសង្គម។ ការលំបាកនេះអាចបណ្តាលមកពីលក្ខណៈបច្ចេកទេសនៃប្រព័ន្ធ និងនីតិនីតិនៃការរៀបចំថវិកា និងការទូទាត់ថវិកាឃុំ សង្កាត់។

ការអូសបន្លាយពេលវេលាក្នុងការចាត់វិធានការដោះស្រាយ និងផ្តល់ការណែនាំដល់រដ្ឋបាលក្រុង ស្រុកក្នុងការប្រើប្រាស់មូលនិធិក្រុង ស្រុកដែលជាការចូលរួមចំណែករបស់ស៊ីដាក៏ជាបញ្ហាប្រឈមដ៏សំខាន់មួយផងដែរ។ បញ្ហានេះបានអូសបន្លាយតាំងពីឆ្នាំ២០១៣ និងបានធ្វើឱ្យរដ្ឋបាលក្រុង ស្រុកពុំអាចធ្វើការសម្រេចចិត្តក្នុងការប្រើប្រាស់នូវមូលនិធិនេះ។ ជាមួយគ្នានេះ ដោយសារមូលនិធិក្រុង ស្រុកមានចំនួនតិចតួច រដ្ឋបាលក្រុង ស្រុកភាគច្រើនបានប្រើប្រាស់មូលនិធិក្រុង ស្រុកនេះស្ទើរតែទាំងស្រុងសម្រាប់រ៉ាប់រងលើការចំណាយផ្នែកចរន្ត ដូចជាប្រាក់បៀវត្សរបស់មន្ត្រី ប្រាក់ឧបត្ថម្ភរបស់ក្រុមប្រឹក្សា និងចំណាយប្រតិបត្តិការរដ្ឋបាលនានា និងប្រើប្រាស់មូលនិធិដែលនៅសេសសល់តិចតួចប៉ុណ្ណោះសម្រាប់គម្រោងអភិវឌ្ឍមូលដ្ឋានដែលជាតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋ។ ជាមួយគ្នានេះ ភាពពុំច្បាស់លាស់នៃការសន្យាផ្តល់ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍក្នុងការចូលរួមចំណែកគាំទ្រដល់មូលនិធិក្រុង ស្រុកផ្នែកអភិវឌ្ឍន៍ក៏ជាកត្តារាំងស្ទះក្នុង

ការសម្រេចបាននូវសូចនាករដែលបានកំណត់ពាក់ព័ន្ធនឹងការបង្កើនមូលនិធិក្រុង ស្រុកផ្នែកអភិវឌ្ឍន៍ឱ្យបានក្នុងកម្រិត០.៥% ធៀបទៅនឹងចំណូលចរន្តប្រចាំឆ្នាំសរុបនៃថវិការដ្ឋផងដែរ។

ក្រៅពីនេះ ភាពយឺតយ៉ាវក្នុងការរៀបចំនូវលិខិតបទដ្ឋានគតិយុត្តសម្រាប់ការរៀបចំយន្តការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌ និងការបង្កើតនូវប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ជាបញ្ហាប្រឈមមួយដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ដោះស្រាយ។ ភាពយឺតយ៉ាវនៃការរៀបចំយន្តការទាំងនេះនឹងធ្វើឱ្យមានការរាំងស្ទះដល់កិច្ចដំណើរការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងអាចប៉ះពាល់ដល់ប្រសិទ្ធភាពនៃការអនុវត្តនូវមុខងារដែលត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៥.៤. ការវិភាគ និងដំណោះស្រាយ

ជាទូទៅ ការធ្វើវិមជ្ឈការគឺជាការផ្ទេរសិទ្ធិអំណាចឱ្យទៅរដ្ឋបាលថ្នាក់មូលដ្ឋានដែលនៅកៀកជិតប្រជាពលរដ្ឋក្នុងការធ្វើសេចក្តីសម្រេចចិត្តលើការប្រើប្រាស់ និងការចាត់ចែងធនធានសម្រាប់ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាននានា សំដៅឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋទៅតាមស្ថានភាពជាក់ស្តែងនៅក្នុងមូលដ្ឋាននីមួយៗ។ វិមជ្ឈការហិរញ្ញវត្ថុ គឺជាសមាសធាតុសំខាន់មួយនៃវិមជ្ឈការ ដែលធានាឱ្យរដ្ឋបាលថ្នាក់មូលដ្ឋានមានប្រភពធនធាន មានធនធាន មានប្រព័ន្ធ និងមាននីតិវិធីសមស្របសម្រាប់គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានទាំងនោះក្នុងការអនុវត្តនូវសេចក្តីសម្រេចចិត្តរបស់ខ្លួនដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

ក្នុងន័យនេះ ភាពស្មុគស្មាញនៃប្រព័ន្ធ និងនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ អាចក្លាយជាហានិភ័យដ៏ចម្បងមួយនៃកំណែទម្រង់វិមជ្ឈការ។ ភាពស្មុគស្មាញទាំងនេះ អាចធ្វើឱ្យរាំងស្ទះដល់ការលើកកម្ពស់ស្វ័យភាព និងការទទួលខុសត្រូវរបស់រដ្ឋបាលទាំងនោះក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្តរបស់ខ្លួន។ ទន្ទឹមគ្នានេះ ភាពមានកម្រិតនៃមូលនិធិក្រុង ស្រុក និងការកើនឡើងជាប្រចាំនូវបន្ទុកចំណាយចរន្តរបស់រដ្ឋបាលក្រុង ស្រុក បានធ្វើឱ្យរដ្ឋបាលក្រុង ស្រុកនីមួយៗស្ទើរតែពុំមានថវិកាសេសសល់សម្រាប់ប្រើប្រាស់ក្នុងការអនុវត្តគម្រោងអភិវឌ្ឍមូលដ្ឋាន និងគម្រោងផ្តល់សេវាសង្គមនានាដែលបានកំណត់ក្នុងផែនការរបស់ខ្លួនឡើយ។ ការអូសបន្លាយស្ថានភាពនេះ ក៏អាចក្លាយជាហានិភ័យមួយនៃកំណែទម្រង់ផងដែរ។

ផ្អែកលើមេរៀន និងបទពិសោធន៍នៃការធ្វើវិមជ្ឈការនៅក្នុងបណ្តាប្រទេសនានាទាំងនៅក្នុង និងក្រៅតំបន់បានបង្ហាញឱ្យឃើញថា ចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់មូលដ្ឋាន គឺជាធនធានដ៏ចម្បងរបស់រដ្ឋបាលថ្នាក់មូលដ្ឋាននីមួយៗ។ ការអនុញ្ញាតឱ្យរដ្ឋបាលថ្នាក់មូលដ្ឋានមានប្រភពចំណូលផ្ទាល់នៅតាមមូលដ្ឋានរបស់ខ្លួន គឺជាកត្តាដ៏ចាំបាច់សម្រាប់ការលើកកម្ពស់នូវស្វ័យភាព និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់មូលដ្ឋានក្នុងការប្រើប្រាស់ ចាត់ចែង និងគ្រប់គ្រងធនធានទាំងនោះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងមូលដ្ឋានរបស់ខ្លួន។ ក្នុងន័យនេះ ភាពយឺតយ៉ាវនៃការបង្កើតប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ មិនត្រឹមតែធ្វើឱ្យរដ្ឋបាលទាំងនោះពុំមានលទ្ធភាពធនធានសម្រាប់ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនោះឡើយ ថែមទាំងជាឧបសគ្គក្នុងការលើក

កម្ពស់ស្វ័យភាព គណនេយ្យភាព និងតម្លាភាពក្នុងការគ្រប់គ្រង ចាត់ចែងការងារផងដែរ។ បញ្ហានេះ អាចក្លាយជាហានិភ័យដ៏គន្លឹះមួយនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តសហការជាមួយក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនានាក្នុងការរៀបចំក្រុមការងារចុះធ្វើការសិក្សាវាយតម្លៃ និងពិនិត្យឡើងវិញទៅលើប្រព័ន្ធ និងនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ដើម្បីឈានទៅកែលំអប្រព័ន្ធ និងនីតិវិធីទាំងនេះនៅឆ្នាំបន្ទាប់។ ជាមួយគ្នានេះ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវបន្តសហការ និងពិភាក្សាពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានាផ្សេងទៀត ក្រៅពីសហភាពអឺរ៉ុបអំពីលទ្ធភាពនៃការគាំទ្រដល់មូលនិធិក្រុង ស្រុកផ្នែកអភិវឌ្ឍន៍ពីឆ្នាំ២០១៦តទៅ។ លើសពីនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏គួរសិក្សាឡើងវិញអំពីលទ្ធភាពក្នុងការផ្តល់បន្ថែមនូវមូលនិធិក្រុង ស្រុកពីថវិការដ្ឋ ដើម្បីធានាឱ្យរដ្ឋបាលក្រុង ស្រុកមានធនធានក្នុងកម្រិតសមស្របសម្រាប់គាំទ្រដល់គម្រោងអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសង្គមនានា ដែលអាចឆ្លើយតបទៅនឹងតម្រូវការចាំបាច់ និងជាអាទិភាពរបស់ប្រជាពលរដ្ឋ។

ជាមួយគ្នានេះ ក្នុងឆ្នាំ២០១៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបន្តសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការសិក្សាវាយតម្លៃលើបទពិសោធន៍ដែលកំពុងអនុវត្តដោយក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងបរិស្ថានដើម្បីឈានទៅរៀបចំនូវលិខិតបទដ្ឋានគតិយុត្តនានាសម្រាប់ការរៀបចំបង្កើតយន្តការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់រ៉ាប់រងលើការអនុវត្តនូវមុខងារទាំងឡាយដែលបានផ្ទេរពីថ្នាក់ជាតិ។ លើសពីនេះ ការបន្តជំរុញឱ្យមានការពិនិត្យ និងសម្រេចលើជម្រើសនានានៃការរៀបចំបង្កើតប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ជាសកម្មភាពជាអាទិភាពដែលត្រូវផ្តោតការយកចិត្តទុកដាក់នៅក្នុងឆ្នាំ២០១៦ខាងមុខផងដែរ។

## III. **ស្ថានភាពហិរញ្ញវត្ថុ**

ថវិកាកញ្ចប់រួមដែលគ្រោងចំណាយសម្រាប់គាំទ្រក្នុងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៥របស់ គ.ជ.អ.ប មានចំនួនសរុបប្រមាណ**១១,៨៥លានដុល្លារ**។ ថវិកាកញ្ចប់រួមនេះ គឺជាកញ្ចប់ថវិកាឆន្ទានុសិទ្ធិរបស់ គ.ជ.អ.ប គាំទ្រដោយទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់ប្រទេសស៊ុយអែដ (Sida) សហភាពអឺរ៉ុប (EU) និងទីភ្នាក់ងារអភិវឌ្ឍន៍ និងសហប្រតិបត្តិការស្វីស (SDC) ។

ក្នុងការអនុវត្តជាក់ស្តែង លេខាធិការដ្ឋាន គ.ជ.អ.ប បានវិភាជន៍ថវិកាកញ្ចប់រួមនេះចំនួនប្រមាណ **១១,៦លានដុល្លារ**ទៅឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធនានាចំនួន២០ដែលជាស្ថាប័នអនុវត្តនៅថ្នាក់ជាតិ និងរដ្ឋបាលរាជធានី ខេត្តទាំងអស់នៅទូទាំងប្រទេសសម្រាប់គាំទ្រដល់ការអនុវត្តផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ២០១៥របស់គ.ជ.អ.ប ដោយផ្អែកតាមសកម្មភាពជាអាទិភាពនានាដែលបានកំណត់ក្នុងសេចក្តីសម្រេចរួមរវាងលេខាធិការដ្ឋាន គ.ជ.អ.ប និងភ្នាក់ងារអនុវត្តទាំងនោះ។

ជារួម ដោយសារការចាប់ផ្តើមអនុវត្តនូវផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៥នេះមានភាពយឺតយ៉ាវ អាស្រ័យហេតុនេះ ថវិកាចំណាយជាក់ស្តែងក្នុងឆ្នាំ២០១៥នេះមានចំនួនសរុបប្រមាណ៩,២

**លាន**ដុល្លារ ឬស្មើនឹង**៧៨%**នៃថវិកាគ្រោងសរុបប៉ុណ្ណោះ។ ស្ថានភាពនៃថវិកាចំណាយតាមសមិទ្ធផលរំពឹងទុកនីមួយៗ និងតាមស្ថាប័នអនុវត្តនីមួយៗមានឆ្លុះបញ្ចាំងក្នុងតារាងចំណាយខាងក្រោម។

**តារាងទី១៖ ថវិកាគ្រោង និងចំណាយតាមសមិទ្ធផលរំពឹងទុក (គិតជាដុល្លារ)**

| ពិពណ៌នាមុខចំណាយ | ថវិកាគ្រោង | ចំណាយ | ភាគរយ |
|---|---|---|---|
| សមិទ្ធផលរំពឹងទុកទី១ | 722.687 | 421.887 | 58% |
| សមិទ្ធផលរំពឹងទុកទី២ | 509.311 | 251.513 | 49% |
| សមិទ្ធផលរំពឹងទុកទី៣ | 857.966 | 707.978 | 83% |
| សមិទ្ធផលរំពឹងទុកទី៤ | 1,466.639 | 754.630 | 51% |
| សមិទ្ធផលរំពឹងទុកទី៥ | 303.445 | 213.130 | 70% |
| បុគ្គលិក និងប្រតិបត្តិការ | 8.005.926 | 6.911.762 | 86% |
| សរុបរួម | 11.865.974 | 9.260.899 | 78% |

## IV. ទិសដៅចម្បងសម្រាប់ឆ្នាំ២០១៦

ផ្អែកលើស្ថានភាព និងបញ្ហាប្រឈមជាគន្លឹះដូចបានរៀបរាប់ខាងលើ ក្នុងឆ្នាំ២០១៦នេះ គ.ជ.អ.ប ត្រូវផ្តោតការយកចិត្តទុកដាក់លើការជំរុញ និងការគាំទ្រដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តនូវកិច្ចការចាំបាច់មួយចំនួនដែលខកខានពុំបានអនុវត្ត ឬបានចាប់ផ្តើមអនុវត្តតែពុំទាន់បានសម្រេចក្នុងឆ្នាំ២០១៥កន្លងមក ដូចខាងក្រោម៖

- **ការរៀបចំកិច្ចប្រជុំរបស់ គ.ជ.អ.ប៖** លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវបន្ថែមការខិតខំ ប្រឹងប្រែងសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំឯកសារ និងកិច្ចការចាំបាច់នានាដើម្បីរៀបចំកិច្ចប្រជុំ គ.ជ.អ.ប ឱ្យបានទៀងទាត់។ ក្នុងឆ្នាំ២០១៦ កិច្ចប្រជុំ គ.ជ.អ.ប គួរផ្តោតជាសំខាន់ទៅលើការពិនិត្យ ពិភាក្សា និងផ្តល់គោលការណ៍ទម្រង់ទិសអំពីការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ អំពីការរៀបចំយន្តការផ្ទេរមូលនិធិមានភ្ជាប់ល័ក្ខខ័ណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ អំពីការកែលំអប្រព័ន្ធនិងនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ អំពីការបង្កើតប្រព័ន្ធគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអំពីការពង្រឹងភាពជាម្ចាស់ និងការចូលរួមរបស់ក្រសួង ស្ថាប័នទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងកិច្ចដំណើរការកំណែទម្រង់។
- **ការរៀបចំយន្តការអធិការកិច្ចទៅលើការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ៖** ក្រសួងមហាផ្ទៃត្រូវបន្តផ្តល់អាទិភាពក្នុងការរៀបចំឱ្យមានការពិគ្រោះយោបល់លើសេចក្តីព្រាងក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់ការធ្វើអធិការកិច្ចលើការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រូវរៀបចំបញ្ចប់ក្របខណ្ឌយុទ្ធសាស្ត្រនេះ ដើម្បីធ្វើជាមូលដ្ឋានក្នុងការរៀបចំសេចក្តីណែនាំ និងចាប់ផ្តើមអនុវត្តការធ្វើអធិការកិច្ចទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួននៅឆ្នាំ២០១៦ខាងមុខនេះ។
- **ការរៀបចំលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ៖** ក្រសួងមុខងារសាធារណៈ និងក្រសួងមហាផ្ទៃត្រូវបន្តសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងជាពិសេសជាមួយរដ្ឋបាលថ្នាក់

ក្រោមជាតិក្នុងការពិគ្រោះយោបល់ និងពិចារណាឱ្យបានហ្មត់ចត់លើខ្លឹមសារនៃសេចក្តីព្រាងលក្ខន្តិកៈដោយឡែក ដើម្បីធានាដល់ការបង្កើតនូវប្រព័ន្ធគ្រប់គ្រងបុគ្គលិកនៅរដ្ឋបាលថ្នាក់ក្រោមជាតិជាតិដែលអាចធានាដល់ការផ្តល់សិទ្ធិអំណាចសមស្របដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ធានាដល់ការលើកទឹកចិត្តដល់មន្ត្រីបុគ្គលិកឱ្យទៅបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងធានាអព្យាក្រឹត្យភាពរបស់មន្ត្រី បុគ្គលិកក្នុងការបំពេញតួនាទីរបស់ខ្លួន ព្រមទាំងបង្កលក្ខណៈងាយស្រួលក្នុងការផ្ទេរមន្ត្រី បុគ្គលិកក្នុងកិច្ចដំណើរការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះ ក្រសួងមុខងារសាធារណៈត្រូវពន្លឿនកិច្ចដំណើរការរៀបចំលិខិតបទដ្ឋានគតិយុត្តនានាសម្រាប់អនុវត្តព្រាងលក្ខន្តិកៈដោយឡែកនេះពីឆ្នាំ២០១៦តទៅ។

• **ការជំរុញការផ្ទេរមុខងារ និងធនធានឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ៖** លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវបន្តកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងសម្របសម្រួល និងផ្តល់ការគាំទ្រដល់ក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីជំរុញមានការចាប់ផ្តើមផ្ទេរមុខងារមួយចំនួនក្នុងវិស័យអប់រំ សុខាភិបាល សង្គមកិច្ច និងអភិវឌ្ឍន៍ជនបទ កសិកម្ម និងធនធានធម្មជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងឆ្នាំ២០១៦ខាងមុខនេះ។

• **ការកែសម្រួលប្រព័ន្ធ និងនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុក្រុង ស្រុក និងឃុំ សង្កាត់៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តសហការជាមួយក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធនានា ក្នុងការរៀបចំក្រុមការងារចុះធ្វើការសិក្សាវាយ និងពិនិត្យឡើងវិញទៅលើប្រព័ន្ធ និងនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ដើម្បីឈានទៅកែលំអប្រព័ន្ធ និងតីវិធីទាំងនេះនៅឆ្នាំ២០១៦។

• **ការបង្កើនមូលនិធិក្រុង ស្រុកផ្នែកអភិវឌ្ឍន៍មូលដ្ឋាន៖** លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវបន្តសហការពិភាក្សាពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានាអំពីលទ្ធភាពនៃការផ្តល់ការគាំទ្រដល់មូលនិធិក្រុង ស្រុកផ្នែកអភិវឌ្ឍន៍សម្រាប់ពីឆ្នាំ២០១៦ និង២០១៧។ លើសពីនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏គួរសិក្សាឡើងវិញអំពីលទ្ធភាពនៃការផ្តល់បន្ថែមនូវមូលនិធិក្រុង ស្រុកពីថវិការដ្ឋ ដើម្បីធានាឱ្យរដ្ឋបាលក្រុង ស្រុកមានធនធានក្នុងកម្រិតសមស្របសម្រាប់គាំទ្រដល់កិច្ចអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសង្គមនានាដែលអាចឆ្លើយតបបានទៅនឹងតម្រូវការចាំបាច់ និងជាអាទិភាពរបស់ប្រជាពលរដ្ឋ។

• **ការរៀបចំយន្តការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌ៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបន្តសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការសិក្សាវាយតម្លៃលើបទពិសោធន៍ដែលកំពុងអនុវត្តដោយក្រសួងអភិវឌ្ឍន៍ជនបទ ដើម្បីឈានទៅរៀបចំលិខិតបទដ្ឋានគតិយុត្តនានាសម្រាប់ការរៀបចំបង្កើតយន្តការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់រ៉ាប់រងលើការអនុវត្តនូវមុខងារទាំងឡាយដែលបានផ្ទេរពីថ្នាក់ជាតិ។

• **ការបង្កើតប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ៖** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបន្តជំរុញឱ្យមានការពិនិត្យ និងកំណត់នូវជម្រើសនានាសម្រាប់បង្កើតប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីដាក់ជូន គ.ជ.អ.ប ពិនិត្យ ពិភាក្សា និងផ្តល់គោលការណ៍តម្រង់ទិសផ្នែកនយោបាយ។

• **ការបន្តកែសម្រួលប្រព័ន្ធផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ៖** ក្រសួងផែនការត្រូវបន្ត សហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាក្នុងការបន្តរៀបចំកែសម្រួល ផ្សព្វផ្សាយសេចក្តី ណែនាំបច្ចេកទេសស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

• **ការបន្តជំរុញការបញ្ជ្រាបយេនឌ័រ លើកកម្ពស់បរិយាប័ន្ន និងសមធម៌សង្គម៖** ក្រសួងកិច្ចការនារី និងលេខាធិការដ្ឋាន គ ប.អ.ជ.ត្រូវបន្តសម្របសម្រួល និងផ្តល់ការគាំទ្រដល់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានាក្នុងការបញ្ជ្រាបកិច្ចការដ៏មានសារៈសំខាន់នេះ ទៅក្នុងប្រព័ន្ធគ្រប់គ្រងរបស់ស្ថាប័នដើម្បីធានាឱ្យបានថា រាល់ការធ្វើសេចក្តីសម្រេចចិត្តនានារបស់ស្ថាប័ននីមួយៗ បានគិតគូរ និងពិចារណាអំពីបញ្ហាយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម។ ទន្ទឹមគ្នានេះ ត្រូវផ្តល់អាទិភាពទៅលើការរៀបចំ និងដាក់ចេញនូវគោលការណ៍ណែនាំស្តីពីការបញ្ជ្រាបយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម បន្តពង្រឹងយន្តការគាំទ្រដល់បណ្តាញស្ត្រីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងជំរុញឱ្យបានខ្លាំងក្លានូវការរៀបចំវគ្គបណ្តុះបណ្តាលជាកាតព្វកិច្ចដល់ថ្នាក់ដឹកនាំនៃរដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅបង្កើនការយល់ដឹងថ្មីៗបន្ថែមទៀតអំពីបញ្ហាយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម។

ក្រៅពីកិច្ចការជាអាទិភាពខាងលើ គ.ជ.អ.ប ក៏ត្រូវបន្តជំរុញ ផ្តល់ការគាំទ្រ និងតាមដាន ត្រួតពិនិត្យលើស្ថាប័នអនុវត្តទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្នុងការចាត់វិធានការអនុវត្តសកម្មភាពជាអាទិភាពនានាផ្សេងទៀត ដើម្បីធានាដល់ការសម្រេចបាននូវចំណុចដៅជាអាទិភាពនានាដែលនឹងត្រូវកំណត់នៅក្នុងផែនការសកម្មភាព និងថវិការបស់ គ.ជ.អ.ប ឆ្នាំ២០១៦។

## V. សេចក្តីសន្និដ្ឋាន

ឆ្នាំ២០១៥នេះ គឺជាអន្តរកាលនៃការផ្ទេរការអនុវត្តផអ៣ទី១ និងការរៀបចំបែបផែនថ្មីសម្រាប់ការចាប់ផ្តើមអនុវត្តផអ៣ទី២។ អាស្រ័យហេតុនេះ ការចាប់ផ្តើមអនុវត្តនូវផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៥នេះមានភាពយឺតយ៉ាវជាងការគ្រោងទុក។ ភាពយឺតយ៉ាវនេះ គឺជាមូលហេតុចម្បងមួយនៃការខកខាន ឬការពុំអាចសម្រេចបាននូវចំណុចដៅជាអាទិភាពមួយចំនួនដែលបានកំណត់នៅក្នុងផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥របស់ គ.ជ.អ.ប។

ទោះបីមានភាពយឺតយ៉ាវនេះក៏ដោយ ក៏ការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០១៥ របស់ គ.ជ.អ.ប នៅក្នុងឆ្នាំ២០១៥នេះ មានស្ថានភាពល្អប្រសើរ និងស្ថាប័នអនុវត្តទាំងអស់ ទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិបានចូលរួមយ៉ាងសកម្ម និងមានការទទួលខុសត្រូវខ្ពស់ក្នុងការអនុវត្តសកម្មភាពជាអាទិភាពនានាដែលបានកំណត់។

ជារួម ផ្អែកតាមប្រព័ន្ធទិន្នន័យសម្រាប់ការរៀបចំ និងការតាមដានការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប (NAD) បានបង្ហាញឱ្យឃើញថា វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ២០១៥របស់ គ.ជ.អ.ប បានសម្រេចតាមសូចនាករនៃចំណុចដៅជាអាទិភាពក្នុងកម្រិត

ប្រមាណពី៧០ទៅ៨០% និងការចំណាយអស់ប្រមាណ៨០% ប្រៀបធៀបទៅនឹងថវិកាចំណាយដែលបានគ្រោង។

ទោះបីយ៉ាងនេះក្តី ដើម្បីធានាឱ្យសម្រេចបាននូវចំណុចដៅជាអាទិភាពដែលកំណត់ នៅក្នុងឆ្នាំ២០១៦ខាងមុខ ស្ថាប័នអនុវត្តទាំងអស់ត្រូវតែបន្តកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដោយផ្តល់អាទិភាពទាំងទៅលើសកម្មភាព ដែលខកខានពុំបានសម្រេចក្នុងឆ្នាំ២០១៥ និងចាប់ផ្តើមអនុវត្តនូវសកម្មភាពជាអាទិភាពថ្មីៗនានា ដែលបានកំណត់នៅក្នុងផអ៣ទី២ ។ ដើម្បីធានាដល់ការសម្រេចបាននូវកិច្ចការទាំងនេះ ក្នុងឆ្នាំ២០១៦ គ.ជ.អ.ប ត្រូវពង្រឹង និងចាត់វិធានការឱ្យបានកាន់តែច្បាស់លាស់ និងជាក់លាក់បន្ថែមទៀតទាំងក្នុងការសម្របសម្រួល ការគាំទ្រ និងការតាមដានត្រួតពិនិត្យលើការចាត់ចែង និងការអនុវត្តការងាររបស់ស្ថាប័នអនុវត្តទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។